ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ២៧ ត្រីមាសទី០២ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


៨-៦-២០២២ -ព្រះរាជក្រម នស/រកម/០៦២២/០០៦ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី សុវត្ថិភាពម្ហូបអាហារ ៣២២៧


### ២~ព្រះរាជក្រឹត្យ


២៥-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/២៩៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការ ៨៧ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍ ៣២៤៣

២៥-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/២៩៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការ ៣១១ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងនិយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ដល់មន្ត្រីរាជការ ៥ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងពាណិជ្ជកម្ម ៣២៤៧

២៥-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/២៩៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ជាណាន** (WANG JIANAN) ជនជាតិចិន សញ្ជាតិចិន ៣២៦៤

២៥-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ហុកខែនប៊ីរី ដាន់ញ៉ែល អូលីវឺ** (HOCKENBERRY DANIEL OLIVER) ជនជាតិម៉ាដាហ្គាស្កា សញ្ជាតិម៉ាដាហ្គាស្កា ដោយប្តូរឈ្មោះជា **មាស ណាវ៉ាត្រា** (MEAS NAVATRA) ៣២៦៥

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តមឧត្តមសេនីយ៍ឯក **មួង ឃីម** ៣២៦៦

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ អស់លោក និងលោកស្រី ចំនួន ៤ រូប ៣២៦៧

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ៧ រូប ៣២៦៨

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់សប្បុរសជន ចំនួន ២៧ រូប ៣២៦៩

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១១៣រូប ៣២៧០

៣០-៣-២០២២ -ព្រះរាជក្រឹត្យ នស/រកត/០៣២២/៣០៦ ស្ដីពី ការតែងតាំងឯកឧត្តម **លីម ម៉ុនហុក** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នីតិកាលទី៤ ៣២៧៣


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៦-៥-២០២២ -អនុក្រឹត្យលេខ ៩២ អនក្រ.បក ស្ដីពី ការកាត់ផ្ទៃដីទំហំ ៣៧៥ ហិកតា ៩៣ អា និង ៤៧ សង់-ទីអា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចព្រៅ ស្ថិតក្នុងភូមិកាទៀង ឃុំល្បាំង១ ស្រុកលំផាត់ ខេត្តរតនគិរី ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៣២៧៤

២០-៥-២០២២ -អនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៣២៧៦

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦១ អនក្រ.តត ស្ដីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣២៩៥

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦២ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូននាយទាហាន ៣២៩៦

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦៣ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៣៣០០

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៣៣០១

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦៥ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៣៣០២

១៨-៤-២០២២ -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៣៣០៥

១៩-៤-២០២២ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្ដីពី ការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ ៣៣០៧

២០-៤-២០២២ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៣៣០៨

២០-៤-២០២២ -អនុក្រឹត្យលេខ ២៦៩ អនក្រ.តត ស្ដីពី ការនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់មន្ត្រីរាជការ ៣៣១០

២០-៤-២០២២ -អនុក្រឹត្យលេខ ២៧០ អនក្រ.តត ស្ដីពី ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣៣១២

២០-៤-២០២២ -អនុក្រឹត្យលេខ ២៧១ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៣៣១៤


### ២~សេចក្តីសម្រេច


១៣-៦-២០២២ -សេចក្ដីសម្រេចលេខ ៤០ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីរំលឹកខួបលើកទី៤៥ នៃទិវាចងចាំ ដំណើរឆ្ពោះទៅការផ្ដួលរំលំរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ២០ មិថុនា ១៩៧៧ ~ ២០ មិថុនា ២០២២ នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច១៦ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ៣៣១៥

| | | |
|---|---|---|
| ១៦-៦-២០២២ | -សេចក្តីសម្រេចលេខ ៤១ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា | ៣៣១៨ |

## ៣~សារាចរណែនាំ

| | | |
|---|---|---|
| ៨-៦-២០២២ | -សារាចរណែនាំលេខ ០៤ សរណន ស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ | ៣៣២២ |

## III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

| | | |
|---|---|---|
| ៩-៦-២០២២ | -ប្រកាសលេខ ៤១៣ សហវ.ប្រក ស្តីពី ការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | ៣៣៤៦ |

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| | | |
|---|---|---|
| ២០-៥-២០២២ | -ប្រកាសលេខ ១៩៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាគផាក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រផលិតសម្ភារវេចខ្ចប់ | ៣៣៤៨ |

# ព្រះរាជក្រម

នស/រកម/០៦២២/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# សុវត្ថិភាពម្ហូបអាហារ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនិងយន្តការសម្រាប់គ្រប់គ្រង និងធានាសុវត្ថិភាព គុណភាព អនាម័យ និងភាពស្របច្បាប់ នៃម្ហូបអាហារ ក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដើម្បីផ្តល់ការការពារសុខភាពនិងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់ និងធានាឱ្យមានការធ្វើពាណិជ្ជកម្មម្ហូបអាហារប្រកបដោយភាពស្មោះត្រង់។

**មាត្រា២ ..**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពម្ហូបអាហារ ដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ និងលើអាជីវកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ..**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ ..**

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចដឹកនាំ សម្របសម្រួលការគ្រប់គ្រងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

## ជំពូកទី៣
## បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និងគោលការណ៍ត្រួតពិនិត្យ

**មាត្រា៥ ..**

ការរៀបចំបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារត្រូវផ្អែកលើ៖

- ស្តង់ដារកម្ពុជាផ្នែកម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ
- ស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដែលបានចេញដោយអង្គការសុវត្ថិភាពម្ហូបអាហារអន្តរជាតិនិងថ្នាក់តំបន់ក្នុងករណីស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំកម្ពុជាមិនបានកំណត់
- តម្រូវការជាក់ស្តែង និងត្រូវឆ្លើយតបទៅនឹងស្ថានភាពនៃសុខភាពមនុស្ស ឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថានភាពសេដ្ឋកិច្ចជាតិ។

បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ត្រូវអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិតាមសំណើរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីក្រុមប្រឹក្សាស្តង់ដារជាតិមិនទាន់មានកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ ក្រសួងពាណិជ្ជកម្មត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីកំណត់បទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារ។

**មាត្រា៦ ..**

ការកំណត់លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥ខាងលើ។

ការកំណត់លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារត្រូវអនុលោមតាមគោលការណ៍ដូចខាងក្រោម៖

(ក) ម្ហូបអាហារត្រូវមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ។

(ខ) ម្ហូបអាហារមិនត្រូវបាននាំចូល ផលិត កែច្នៃ ឬលក់ ក្នុងលក្ខណៈក្លែងបន្លំឬបំភាន់។

(គ) អ្នកប្រើប្រាស់បានទទួលព័ត៌មានគ្រប់គ្រាន់អំពីម្ហូបអាហារ ដូចជាប្រភពដើម គ្រឿងផ្សំ តម្លៃ អាហារូបត្ថម្ភ និងចំនួនកាឡូរី របៀបប្រើប្រាស់ និងការរក្សាទុក។

(ឃ) ម្ហូបអាហារត្រូវបំពេញតាមលក្ខខណ្ឌអនាម័យ ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា។

(ង) ម្ហូបអាហារដែលត្រូវបានចាត់ថាជាប្រភេទមានហានិភ័យខ្ពស់ ត្រូវចុះបញ្ជិកាឱ្យបានត្រឹមត្រូវ។

(ច) ការស្តុកទុកឬទីតាំងស្តុកម្ហូបអាហារ ត្រូវបំពេញតាមលក្ខខណ្ឌសម្រាប់ការរក្សាសុវត្ថិភាព និងគុណភាពរបស់ម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយនូវរាល់ព័ត៌មានថ្មីៗអំពីលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

**មាត្រា៧.-**

ការត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវធ្វើឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារនៅគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ តាមតួនាទីនិងភារកិច្ចរៀងៗខ្លួន៖

(ក) ផ្អែកលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដែលនឹងត្រូវកំណត់ស្របតាមមាត្រា៦ខាងលើ ហើយក្នុងករណីចាំបាច់ ត្រូវផ្អែកលើស្តង់ដារម្ហូបអាហារ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំអន្តរជាតិ ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

(ខ) ផ្អែកលើការសិក្សាវាយតម្លៃហានិភ័យ ដោយឈរលើមូលដ្ឋាននៃភស្តុតាងវិទ្យាសាស្ត្រដែលមាននិងត្រូវបានអនុវត្តក្នុងរបៀបមួយដែលឯករាជ្យ សត្យានុម័ត និងមានតម្លាភាព។

(គ) មានសមាមាត្រចំពោះហានិភ័យនេះ។

(ឃ) មិនតម្រូវឱ្យមានលក្ខណៈតឹងរ៉ឹងជាងភាពចាំបាច់នៃការត្រួតពិនិត្យ។

(ង) មិនត្រូវបង្កើតឧបសគ្គដែលមិនចាំបាច់ដល់ដំណើរការពាណិជ្ជកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច។

(ច) មិនឱ្យមានការរើសអើងរវាងផលិតផល ឬផលិតករក្នុងស្រុក ឬបរទេស ឬក្នុងចំណោមប្រទេសផ្សេងទៀតនៅពេលដែលមានលក្ខខណ្ឌដូចគ្នាឬប្រហាក់ប្រហែលគ្នា។

**មាត្រា៨.-**

ក្នុងករណីដែលត្រូវឆ្លើយតបនឹងស្ថានភាពបន្ទាន់នៃសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវចេញបទប្បញ្ញត្តិដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់នោះ។ ការដាក់កំហិតបន្ថែមនោះ ត្រូវមានរយៈពេលកំណត់ជាក់លាក់ និងត្រូវបានពិនិត្យឡើងវិញ ក្នុងកំលុងពេលកំណត់មួយ។ នៅពេលដែលលែងមានស្ថានភាពបន្ទាន់ហើយនោះ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវលុបចោលការដាក់កំហិតបន្ថែមលើលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារនោះវិញ តាមសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៩.-**

រាល់អាជីវកម្មម្ហូបអាហារ ត្រូវមានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ រាល់ការចេញលិខិតអនុញ្ញាតត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

រាល់បុគ្គលទាំងឡាយណា ដែលបានប្រកបអាជីវកម្មម្ហូបអាហារ ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១០.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ក្រុមនៃប្រភេទអាជីវកម្មម្ហូបអាហារ និងត្រូវបង្កើតលក្ខខណ្ឌតម្រូវផ្សេងៗគ្នាដោយផ្អែកលើៈ

(ក) ប្រភេទនៃទីកន្លែងអាជីវកម្ម។

(ខ) ប្រភេទនៃប្រតិបត្តិការអាជីវកម្ម។

(គ) ប្រភេទនៃម្ហូបអាហារ។

ការដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារខាងលើ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវរក្សាបញ្ជីនិងធ្វើបច្ចុប្បន្នភាពនៃប្រតិបត្តិករអាជីវកម្មម្ហូបអាហារទាំងអស់ ក្រោយពីបានផ្តល់/ទទួលលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១១.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារមានកាតព្វកិច្ចជាចម្បងដូចខាងក្រោមៈ

- ត្រូវធានាថាម្ហូបអាហារមានសុវត្ថិភាព គុណភាព និងភាពសមស្របសម្រាប់មនុស្សបរិភោគ ស្របតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ
- ត្រូវដោះស្រាយបញ្ហាសុវត្ថិភាពម្ហូបអាហារនៅពេលដែលកើតមាននៅក្នុងអាជីវកម្មរបស់ខ្លួន
- ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ
- ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១២.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ ហើយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ក្នុងការអនុវត្តវិធានការដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យដែលបានបង្កដោយផលិតផលនៃអាជីវកម្មម្ហូបអាហារដែលពាក់ព័ន្ធ ព្រមទាំងការអង្កេតដាន ការប្រមូលម្ហូបអាហារមកវិញ និងការដកហូតម្ហូបអាហារ។

**មាត្រា១៣.-**

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារដាក់លក់មួយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងបទប្បញ្ញត្តិបច្ចេកទេសម្ហូបអាហារដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ និងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ផលិតករ អ្នកកែច្នៃ ឬអ្នកវេចខ្ចប់ម្ហូបអាហារមិនត្រូវៈ

(ក) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ពុំមានសុវត្ថិភាព។

(ខ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយបន្លំម៉ាក ឬមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់ ឬដាក់ស្លាកសញ្ញាមិនអនុលោមតាមលក្ខខណ្ឌស្តីពីស្លាកសញ្ញាដូចមានចែងក្នុងស្តង់ដារកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់។

(គ) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករនៃម្ហូបអាហារ។

(ឃ) ស្តុកទុក ឬធ្វើសហគ្គាករណ៍ ឬទុកដាក់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា១៤ .-**

អាជីវករលក់ដុំ និងអាជីវករចែកចាយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្នុងប្រតិបត្តិការអាជីវកម្មលក់ដុំ និងអាជីវកម្មចែកចាយ អាជីវករលក់ដុំ ឬអាជីវករចែកចាយមិនត្រូវ៖

(ក) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ខ) រក្សាទុក លក់ដុំ ឬចែកចាយម្ហូបអាហារ ដែលផ្ទុយនឹងសេចក្តីណែនាំអំពីសុវត្ថិភាពរបស់ផលិតករ។

(គ) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារពុំមានសុវត្ថិភាព ឬបន្លំម៉ាក។

(ឃ) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ដែលមិនអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករនៃម្ហូបអាហារ។

(ង) ផ្គត់ផ្គង់ លក់ដុំ ឬចែកចាយម្ហូបអាហារ ដោយដឹងថាពុំមានសុវត្ថិភាព។

(ច) រក្សាទុក ឬធ្វើសហត្ថាករណ៍ ឬទុកដាក់ ដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា១៥ .-**

អាជីវករលក់រាយ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ព្រមទាំងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និងបទប្បញ្ញត្តិនានាដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

ក្នុងប្រតិបត្តិការអាជីវកម្មលក់រាយ អាជីវករលក់រាយ មិនត្រូវ៖

(ក) ដាក់លក់ម្ហូបអាហារ ក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ខ) ធ្វើសហត្ថាករណ៍ ឬទុកដាក់ម្ហូបអាហារក្នុងស្ថានភាពគ្មានអនាម័យ។

(គ) ដាក់ស្លាកសញ្ញាគ្រប់ប្រភេទពុំត្រឹមត្រូវ។

(ឃ) ដាក់លក់ម្ហូបអាហារ ដែលមិនអាចបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករ និង/ឬអ្នកចែកចាយនៃម្ហូបអាហារ។

(ង) លក់ម្ហូបអាហារ ដោយដឹងថាពុំមានសុវត្ថិភាព ឬបន្លំម៉ាក។

**មាត្រា១៦ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ មានសិទ្ធិធ្វើការអង្កេតដាន និងដកហូតម្ហូបអាហារមកវិញ តាមប្រភេទអាជីវកម្មម្ហូបអាហារ ដែលប៉ះពាល់ដល់សុខភាពមនុស្ស៖

(ក) តាមដានថយក្រោយមួយជំណាក់ម្តងៗពីបុគ្គលដែលផ្គត់ផ្គង់សាច់សត្វ ឬវត្ថុធាតុដើមផ្សេងៗទៀត និងសារធាតុផ្សំ សម្រាប់ផលិតម្ហូបអាហារ ឬសារធាតុដែលនឹងប្រើសម្រាប់ ឬរំពឹងថានឹងត្រូវដាក់បញ្ចូលទៅក្នុងម្ហូបអាហារ។

(ខ) តាមដានទៅមុខមួយជំណាក់ម្តងៗលើអ្នកទិញដែលជាអ្នកផ្សេង ក្រៅពីអ្នកប្រើប្រាស់ចុងក្រោយ។

(គ) កំណត់អត្តសញ្ញាណនៃឡូត៍នៅកន្លែងទទួល នៅកន្លែងផលិតម្ហូបអាហារ ឬបរិមាណនៃម្ហូបអាហារដែលផលិតចេញពីសាច់សត្វ ឬវត្ថុធាតុដើម និងសារធាតុផ្សំផ្សេងៗទៀតដែលត្រូវបានដាក់បញ្ចូលក្នុងម្ហូបអាហារ ឬបញ្ជូនមកកន្លែងផលិត។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាន និងការដកហូតម្ហូបអាហារ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៧ .-**

ប្រតិបត្តិការអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តតាមលក្ខខណ្ឌអនាម័យម្ហូបអាហារដែលបានកំណត់ក្នុងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ និង/ឬក្នុងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអនាម័យម្ហូបអាហារ។

**មាត្រា១៨ ._**

រាល់ម្ហូបអាហារដែលវេចខ្ចប់ស្រេចសម្រាប់លក់ ត្រូវមានស្លាកសញ្ញា ដូចបានកំណត់ក្នុងលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារនិងក្នុងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ព្រមទាំងបទប្បញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងស្លាកសញ្ញាដូចមានចែងក្នុងស្តង់ដារកម្ពុជាស្តីពីការដាក់ស្លាកសញ្ញាម្ហូបអាហារវេចខ្ចប់។

រាល់ស្លាកសញ្ញាទាំងនោះត្រូវ៖

(ក) មានព័ត៌មានដែលអាចអង្កេតដានបាន។

(ខ) សរសេរជាភាសាខ្មែរ យ៉ាងហោចណាស់ចំពោះចំណុចដែលពាក់ព័ន្ធនឹងសុវត្ថិភាពម្ហូបអាហារ និងកិច្ចការការពារអ្នកប្រើប្រាស់ ហើយនៅពេលដែលស្លាកសញ្ញាដើមមិនមែនជាភាសាខ្មែរ អាចប្រើប្រាស់ស្លាកសញ្ញាភាសាខ្មែរបន្ថែមពីលើដំនួសឱ្យការដាក់ស្លាកសញ្ញាសាជាថ្មី។

(គ) កំណត់ពីព័ត៌មានពិស្តារ ដែលអាចត្រូវបានបញ្ញត្តិ ដោយរួមមាននូវព័ត៌មានពីអាហារូបត្ថម្ភ។

(ឃ) មិនមានព័ត៌មាន ឬរូបភាពណាមួយ ដែលផ្ទុយពីព័ត៌មាននៅលើស្លាកសញ្ញា ឬលក្ខខណ្ឌតម្រូវស្តីពីស្លាកសញ្ញាណាមួយដែលបានបញ្ញត្តិ ឬមិនត្រូវធ្វើឱ្យយល់ខុស ឬក្លែងបន្លំអ្នកប្រើប្រាស់នៅក្នុងលក្ខណៈណាមួយនោះទេ។

(ង) អាចអានបាន ឬមិនត្រូវបាំងដោយវត្ថុវេចខ្ចប់ខាងក្រៅប្រសិនបើមាន។

បែបបទនិងលក្ខខណ្ឌនៃការដាក់ស្លាកសញ្ញា ត្រូវកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា១៩ ._**

ត្រូវហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ ទោះតាមទម្រង់ណាក៏ដោយ ដែលមានលក្ខណៈភូតកុហកពង្វាងការពិត ឬការអះអាងណាមួយដែលមិនពិត ការក្លែងបន្លំ ឬការធ្វើឱ្យមានការភាន់ច្រឡំអំពីលក្ខណៈពិតនៃគុណភាពនិងសុវត្ថិភាពម្ហូបអាហារដូចជា៖

(ក) ការរំពឹងទុកនៃផលិតផល។

(ខ) អត្តសញ្ញាណ ប្រភេទ យថាប្រភេទ ប្រភព លក្ខណៈ រូបរាង ឬអាហារូបត្ថម្ភ។

(គ) គុណភាព ធាតុផ្សំ បរិមាណ របៀបនៃការកែច្នៃផលិត និងកាលបរិច្ឆេទនៃការផលិត។

(ឃ) កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ វិធីណែនាំ និងលក្ខខណ្ឌនៃការប្រើប្រាស់។

(ង) វិធីសាស្ត្រនៃការលក់ ការអាចរកទិញបាននៃផលិតផល និងតម្លៃ។

(ច) ការធានាអះអាងផ្សេងៗដែលលើសពីភាពពិត។

ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ កំណត់អំពីលក្ខខណ្ឌតម្រូវសម្រាប់ការផ្សាយពាណិជ្ជកម្មផលិតផលម្ហូបអាហារ។

**មាត្រា២០ ._**

ក្រសួងពាណិជ្ជកម្ម ត្រូវបង្កើតឱ្យមានប្រព័ន្ធឆ្លើយតបដល់សាធារណជន ពាក់ព័ន្ធនឹងបញ្ហាគុណភាព សុវត្ថិភាពម្ហូបអាហារ ការដាក់ស្លាកសញ្ញាម្ហូបអាហារ ឬបណ្តឹងនានាពាក់ព័ន្ធនឹងអាជីវកម្មម្ហូបអាហារ ឬបញ្ហាសុវត្ថិភាពម្ហូបអាហារដទៃទៀតនៅលើទីផ្សារ។

**មាត្រា២១ ._**

ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវរៀបចំឱ្យមានលក្ខណវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ ដើម្បីធ្វើការវិភាគ ស្របតាមគោលបំណងនៃច្បាប់នេះ។

លក្ខណវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៤
## ការធ្វើអធិការកិច្ចម្ហូបអាហារ

**មាត្រា២២.-**

ការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចម្ហូបអាហាររបស់ក្រសួងពាណិជ្ជកម្មនិង/ឬដោយមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ទៅតាមដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្ម តាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ដើម្បីលើកកម្ពស់គុណភាពនិងសុវត្ថិភាពម្ហូបអាហារ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារត្រូវ៖

(ក) បង្កើតប្រព័ន្ធអធិការកិច្ចម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃការសិក្សាវាយតម្លៃហានិភ័យ។

(ខ) កំណត់ប្រព័ន្ធចំណាត់ថ្នាក់ហានិភ័យសម្រាប់អាជីវកម្មម្ហូបអាហារ និងកំណត់ប្រភេទអាជីវកម្មជាក់លាក់នៅក្រោមប្រព័ន្ធចំណាត់ថ្នាក់នោះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

**មាត្រា២៣.-**

មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចម្ហូបអាហារនៃក្រសួងពាណិជ្ជកម្ម ឬមន្ត្រីអធិការកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៤.-**

មន្ត្រីអធិការកិច្ចម្ហូបអាហារដូចមានចែងក្នុងមាត្រា២២នៃច្បាប់នេះ ដែលត្រូវចុះបំពេញភារកិច្ចក្នុងបរិវេណនិងក្នុងទីតាំងធ្វើអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៥.-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវរក្សាព័ត៌មានដែលបានរកឃើញក្នុងកំលុងពេលនៃការធ្វើអធិការកិច្ចជាការសម្ងាត់ លើកលែងតែមានការអនុញ្ញាតពីប្រធានស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬតុលាការតម្រូវឱ្យលាតត្រដាងព័ត៌មាននោះ។

## ជំពូកទី៥
## ម្ហូបអាហារនាំចូល

**មាត្រា២៦.-**

ការនាំចូលម្ហូបអាហារ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដូចមានចែងក្នុងច្បាប់នេះ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការនាំចូលម្ហូបអាហារអាចតម្រូវឱ្យមានភ្ជាប់វិញ្ញាបនបត្រដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចេញ ស្របទៅតាមគោលការណ៍គ្រប់គ្រងហានិភ័យដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

បញ្ជីម្ហូបអាហារដែលជាកម្មវត្ថុសម្រាប់តម្រូវការឯកសារ និងលក្ខខណ្ឌនៃការនាំចូល ត្រូវកំណត់ដោយ

**មាត្រា២៧ .-**

ក្នុងករណីចាំបាច់ដែលម្ហូបអាហារនាំចូលតម្រូវឱ្យមានការធ្វើវិភាគ ដើម្បីផ្ទៀងផ្ទាត់ភាពអនុលោមតាមលក្ខខណ្ឌតម្រូវស្ដីពីម្ហូបអាហារ សំណាកគំរូ ត្រូវយកមកធ្វើការវិភាគដោយមន្ទីរពិសោធន៍ជំនាញដូចមានចែងក្នុងមាត្រា២១នៃច្បាប់នេះ។

**មាត្រា២៨ .-**

ម្ហូបអាហារនាំចូលដែលមិនអនុលោមតាមច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ត្រូវសម្រេចចាត់ចែងដូចខាងក្រោម៖

(ក) តម្រូវឱ្យនាំចេញទៅវិញ។

(ខ) តម្រូវឱ្យកែច្នៃសាជាថ្មី រួមទាំងការដាក់ស្លាកសញ្ញាជាថ្មី និងបញ្ជូនទៅធ្វើការត្រួតពិនិត្យជាផ្លូវការម្ដងទៀត។

(គ) កម្ទេចចោល។

រាល់ការចំណាយពាក់ព័ន្ធជាបន្ទុករបស់អ្នកនាំចូល។

## ជំពូកទី៦
## ម្ហូបអាហារដែលចរាចរនៅលើទីផ្សារ

**មាត្រា២៩ .-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវធ្វើការត្រួតពិនិត្យនិងអង្កេតនៅតាមទីផ្សារ ចំពោះផលិតផលដែលមានហានិភ័យខ្ពស់និងចំពោះផលិតផលដែលទទួលបានព័ត៌មានថាមានហានិភ័យ ដោយផ្អែកលើមូលដ្ឋានព័ត៌មានដែលបញ្ជាក់អំពីហានិភ័យ ហើយត្រូវសមាមាត្រទៅនឹងកម្រិតហានិភ័យដែលមានក្នុងម្ហូបអាហារនោះ។

ក្នុងករណីចាំបាច់ មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវយកគំរូនៅតាមទីផ្សារមកវិភាគនៅមន្ទីរពិសោធន៍ និងធ្វើការកត់ត្រាអំពីលទ្ធផល និងមានវិធានការតាមនីតិវិធីបន្ត។

**មាត្រា៣០ .-**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវសម្រេចចាត់ចែងចំពោះម្ហូបអាហារនៅលើទីផ្សារដែលមិនអនុលោមតាមលក្ខខណ្ឌតម្រូវនានាដែលបានបញ្ញត្តិក្នុងច្បាប់ និងក្នុងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងនឹងម្ហូបអាហារ ដូចខាងក្រោម៖

(ក) ឱ្យធ្វើការកែតម្រូវឡើងវិញ។

(ខ) តម្រូវឱ្យកែច្នៃសាជាថ្មី។

(គ) រឹបអូសនិងកម្ទេចចោល ក្នុងករណីដែលមិនអាចកែតម្រូវឬកែច្នៃសាជាថ្មីបាន។

រាល់ការចំណាយពាក់ព័ន្ធជាបន្ទុករបស់ម្ចាស់ម្ហូបអាហារ។

## ជំពូកទី៧
## ម្ហូបអាហារនាំចេញ

**មាត្រា៣១ .-**

ការនាំចេញម្ហូបអាហារ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនានារបស់ប្រទេសនាំចូលស្របតាមកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគីដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៨
## កម្រៃសេវា

**មាត្រា៣២ .-**

កម្រៃសេវា ដែលស្ថិតក្រោមក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងដែលទទួលបន្ទុកពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## ទោសប្បញ្ញត្តិ

**មាត្រា៣៣ .-**

ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរ ឬដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- ការបិទអាជីវកម្ម។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងការបិទអាជីវកម្ម ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារដែលចេញលិខិតអនុញ្ញាតទាំងនោះ និង/ឬស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចម្ហូបអាហារ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចម្ហូបអាហារមានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅតុលាការ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រមូលប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៤ .-**

ត្រូវពិន័យអន្តរការណ៍ពី៥០០ ០០០(ហាសិបម៉ឺន)រៀលទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

(ក) ដំណើរការអាជីវកម្មម្ហូបអាហារ ដោយមិនមានលិខិតអនុញ្ញាត។

(ខ) រៀបចំ ស្តុកទុក ធ្វើសហគ្គាករណ៍ ឬលក់ម្ហូបអាហារ ដែលខ្វះអនាម័យ។

(គ) មិនបានជូនដំណឹងជាបន្ទាន់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ អំពីបញ្ហាដែលកើតឡើងចំពោះម្ហូបអាហារ។

(ឃ) មិនបានបង្កើត និងអនុវត្តប្រព័ន្ធដែលអាចអង្កេតដាន ដែលបានកំណត់ក្នុងច្បាប់នេះ។

(ង) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារ ដោយមិនមានបញ្ជាក់អំពីអត្តសញ្ញាណរបស់ផលិតករ និង/ឬអ្នកចែកចាយម្ហូបអាហារ។

(ច) ផលិត កែច្នៃ ឬវេចខ្ចប់ម្ហូបអាហារដែលមិនមានដាក់កាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ឆ) ផ្គត់ផ្គង់ លក់ដុំ ចែកចាយ ឬដាក់លក់ម្ហូបអាហារក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

(ជ) មិនបានគោរពតាមវិធានអនាម័យ ដែលត្រូវកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ។

(ឈ) មិនបានផ្តល់ព័ត៌មានអំពីខ្លឹមសារដែលបញ្ជាក់ពីគុណភាព សុវត្ថិភាពនៃម្ហូបអាហារ ដែលនឹងត្រូវផ្សាយដំណឹងពាណិជ្ជកម្ម។

(ញ) មិនបានគោរពតាមការណែនាំនិងការកែតម្រូវរបស់មន្ត្រីអធិការកិច្ចម្ហូបអាហារ។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣៤នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៥ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារនៃរោងចក្រនិងសហគ្រាសធុនតូចនិងមធ្យម ដែលផ្គត់ផ្គង់ លក់ដុំ ចែកចាយ ឬដាក់លក់ម្ហូបអាហារក្រោយកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលប្រើប្រាស់។

**មាត្រា៣៦ .-**

ត្រូវពិន័យអន្តរការណ៍ពី២ ០០០ ០០០(ពីរលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារដែលបញ្ញត្តិក្នុងមាត្រា៦នៃច្បាប់នេះ។

ក្នុងករណីទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា៣៦នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៧ .-**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ដែលផ្សាយពាណិជ្ជកម្ម ឬធ្វើឱ្យមានការផ្សាយពាណិជ្ជកម្មដែលមិនពិត ឬធ្វើឱ្យយល់ខុស ឬធ្វើឱ្យមានការភាន់ច្រឡំអំពីលក្ខណៈពិតនៃម្ហូបអាហារ ត្រូវពិន័យអន្តរការណ៍ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា៣៧នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រា៣៧នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៨ .-**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះប្រតិបត្តិករអាជីវកម្មម្ហូបអាហារដែលដាក់ស្លាកសញ្ញាម្ហូបអាហារដែលមានលក្ខណៈមិនពិត ធ្វើឱ្យយល់ខុស ឬក្លែងបន្លំ អំពីលក្ខណៈពិតនៃម្ហូបអាហារ ត្រូវពិន័យអន្តរការណ៍ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

ក្នុងករណីទទួលនូវការពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា៣៨នៃច្បាប់នេះ ត្រូវទទួលការពិន័យអន្តរការណ៍ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកទី១។

ករណីនៅតែបន្តប្រព្រឹត្តល្មើសនូវអំពើដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រា៣៨នៃច្បាប់នេះ មន្ត្រីអធិការកិច្ចម្ហូបអាហារត្រូវធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ដើម្បីសម្រេចក្នុងការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ឬព្យួរ ឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**មាត្រា៣៩ .-**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២០០ ០០០ ០០០(ពីររយលាន)រៀលទៅ៤០០ ០០០ ០០០(បួនរយលាន)រៀល ចំពោះអំពើផលិត កែច្នៃ វេចខ្ចប់ ចែកចាយ ឬលក់ម្ហូបអាហារដោយដឹងថាម្ហូបអាហារនោះមានផ្ទុកនូវសារធាតុពុល ឬសារធាតុបង្កគ្រោះថ្នាក់ដែលលើសកម្រិតអនុញ្ញាត ដែលនាំឱ្យខូចសុខភាពដល់មនុស្ស។

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត កាលបើអំពើនោះបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងសុវត្ថិភាពអ្នកប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ។

ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌផ្សេងទៀត កាលបើអំពើនោះបង្កឱ្យមានពិការភាពអចិន្ត្រៃយ៍ ឬបាត់បង់អាយុជីវិតរបស់អ្នកប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ។

**មាត្រា៤០ .-**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានក្នុងមាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសបន្ថែមណាមួយឬច្រើនដូចតទៅ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា១៧៤(ការហាមឃាត់ចំពោះការធ្វើការអំពាវនាវជាសាធារណៈឱ្យសន្សំសំចៃ)នៃក្រមព្រហ្មទណ្ឌ។

៦- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៧- ការរឹបអូសផលទុននិងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៨- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៩- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៤១ .–**

មន្ត្រីអធិការកិច្ចម្ហូបអាហារ ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្ដាលឱ្យប៉ះពាល់ដល់សិទ្ធិ បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីអធិការកិច្ចម្ហូបអាហារ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលបានប្រព្រឹត្តសកម្មភាពណាមួយដូចខាងក្រោម៖

(ក) រឹបអូសម្ហូបអាហារដោយមូលហេតុណាមួយ ក្រៅពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់នេះ។

(ខ) លាតត្រដាងព័ត៌មានណាមួយ ដែលបានទទួលក្នុងពេលបំពេញភារកិច្ចរបស់ខ្លួនក្រោមច្បាប់នេះ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ ឬត្រូវបានតម្រូវដោយតុលាការឱ្យលាតត្រដាងព័ត៌មានពាក់ព័ន្ធនោះ ឬមានការអនុញ្ញាតដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តជាធរមានដោយឡែក។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា៤២ .–**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាព និងភាពសមស្របនៃម្ហូបអាហារហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៤៣ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ ពុធ ៩ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០២២

នស/រកម.០៦២២.០២៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
## សទ្ទានុក្រម

១. **ការកែច្នៃ** សំដៅដល់សកម្មភាពណាមួយដែលបម្លែងឬផ្លាស់ប្តូរទម្រង់ដើមនៃផលិតផល។

២. **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់ការបង្ហាញនានា ជាលាយលក្ខណ៍អក្សរ រូបភាព តាមមធ្យោបាយសោតទស្សន៍ ឬតាមមធ្យោបាយផ្សេងទៀត ដែលធ្វើឡើងដើម្បីផ្សព្វផ្សាយលើកកម្ពស់ដោយផ្ទាល់ឬប្រយោលនូវការលក់ ការផ្តល់សេវាម្ហូបអាហារ ឬសារធាតុណាមួយដែលចាត់ទុកថាជាម្ហូបអាហារ។

៣. **ការសិក្សាវាយតម្លៃហានិភ័យ** សំដៅដល់ការវាយតម្លៃលើផលប៉ះពាល់ដល់សុខភាពតាមបែបវិទ្យាសាស្ត្រ ដែលបណ្តាលមកពីភ្នាក់ងារបង្កគ្រោះជីវសាស្ត្រ គីមីសាស្ត្រ និងរូបវន្ត ដោយចែកចេញជាបួនជំហានរួមមាន៖

   ១. ការកំណត់អត្តសញ្ញាណភ្នាក់ងារបង្កគ្រោះ។

   ២. ការកំណត់ចរិតលក្ខណៈភ្នាក់ងារបង្កគ្រោះ។

   ៣. ការវាយតម្លៃអំពីផលរងទទួល។

   ៤. ការកំណត់ចរិតលក្ខណៈហានិភ័យ។

៤. **ការវេចខ្ចប់** សំដៅដល់សកម្មភាពវេចខ្ចប់ម្ហូបអាហារស្របតាមលក្ខខណ្ឌតម្រូវនានា ដើម្បីធានាគុណភាពសុវត្ថិភាពរបស់ផលិតផលម្ហូបអាហារចុងក្រោយសម្រាប់អ្នកប្រើប្រាស់។

៥. **ខ្សែចង្វាក់ម្ហូបអាហារ** សំដៅដល់រាល់ដំណាក់កាលទាំងអស់របស់ផលិតកម្មម្ហូបអាហារ ដោយរាប់ចាប់ពីការផលិតដំបូង រហូតដល់ការចាត់ចែង និងការលក់ម្ហូបអាហារ ដំណាក់កាលរាប់ចាប់ពីកសិដ្ឋានផលិតដល់កន្លែងបរិភោគ។

៦. **ភាពសមស្របនៃម្ហូបអាហារ** សំដៅដល់ម្ហូបអាហារដែលមានលក្ខណៈធម្មជាតិ មានអនាម័យ មានសុវត្ថិភាព និងមិនមានលាយសារធាតុមិនសុទ្ធ។

៧. **ទីកន្លែងអាជីវកម្មម្ហូបអាហារ** សំដៅដល់អគារ តង់ ឬចនាសម្ព័ន្ធផ្សេងទៀត ទាំងអចិន្ត្រៃយ៍ ទាំងបណ្តោះអាសន្ន ស្ថិតនៅលើដីនិងទីកន្លែងជាប់នោះ ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្ម ការវេចខ្ចប់ ការដឹកជញ្ជូន ការចាត់ចែង ការបម្រើសេវា ការស្តុកទុក ឬការលក់ម្ហូបអាហារប្រភេទណាមួយ។

៨. **ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ** សំដៅដល់ម្ចាស់អាជីវកម្មម្ហូបអាហារ ឬបុគ្គលដែលត្រូវបានប្រគល់សិទ្ធិក្នុងការប្រតិបត្តិអាជីវកម្មម្ហូបអាហារ ឬបុគ្គលទទួលខុសត្រូវលើអាជីវកម្មម្ហូបអាហារ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដូចជាផលិតករ អ្នកកែច្នៃ អ្នកវេចខ្ចប់ អាជីវករលក់ដុំ អាជីវករចែកចាយ និងអាជីវករលក់រាយ ជាដើម។

៩. **ប្រព្រឹត្តិកម្ម** សំដៅដល់ការដាក់ពណ៌ ការជ្រលក់ពណ៌ ការដាក់ម្សៅ ការខាត់ ការស្រោច ការលាយ ការរក្សាទុក ការដាក់រសជាតិ ការពង្រាវ ការធ្វើឱ្យខាប់ជាមួយនឹងសារធាតុណាមួយ ការកម្តៅ ឬការសម្លាប់មេរោគ។

១០. **ការអង្កេតដាន** សំដៅដល់សកម្មភាពតាមរកដាននៃការចល័តនៃម្ហូបអាហារ តាមដំណាក់កាលជាក់លាក់នៃផលិតកម្ម ការកែច្នៃ និងការចែកចាយ។

១១. **សារធាតុបង្កគ្រោះថ្នាក់** សំដៅដល់សារធាតុគីមីដែលត្រូវបានប្រើលើសកម្រិតអនុញ្ញាតនៃបទដ្ឋានជាតិ ឬអន្តរជាតិ មានសក្តានុពលបង្កផលប៉ះពាល់អវិជ្ជមានដល់សុខភាព។

១២. **មន្ត្រីអធិការកិច្ចម្ហូបអាហារ** សំដៅដល់មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ដែលត្រូវបានចាត់តាំងស្របតាមមាត្រា២៣នៃច្បាប់នេះ។

១៣. **ម្ហូបអាហារ** សំដៅដល់ផលិតផលឬសារធាតុណាមួយ ទោះបីត្រូវកែច្នៃទាំងស្រុង ឬពាក់កណ្តាលកែច្នៃឬមិនទាន់កែច្នៃ សម្រាប់មនុស្សបរិភោគ រួមទាំងភេសជ្ជៈ ស្ករកៅស៊ូ និងសារធាតុទាំងឡាយ ដែលត្រូវបានប្រើប្រាស់នៅក្នុងផលិតកម្ម ការរៀបចំ ឬការធ្វើប្រព្រឹត្តិកម្មនៃម្ហូបអាហារ លើកលែងតែគ្រឿងសម្អាង ផលិតផលថ្នាំជក់ ឬផលិតផលដែលប្រើប្រាស់សម្រាប់ឱសថ។

១៤. **ម្ហូបអាហារលក់តាមផ្លូវ** សំដៅដល់ម្ហូបអាហាររៀបចំរួចជាស្រេចឬរៀបចំភ្លាមៗ សម្រាប់ដាក់លក់នៅតាមផ្លូវ ទីផ្សារ និងនៅតាមទីកន្លែងសាធារណៈផ្សេងៗ។

១៥. **យាន** សំដៅដល់គ្រប់មធ្យោបាយដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនម្ហូបអាហារពីកន្លែងមួយទៅកន្លែងមួយទៀត។

១៦. **លក់** សំដៅដល់សកម្មភាព ដូចជាស្នើលក់ ផ្សាយដំណឹងពាណិជ្ជកម្ម រក្សាទុក ស្តុកទុក ដាក់បង្ហាញ បញ្ជូនផ្ញើទុក ផ្ទេរ ឬប្រគល់ឱ្យ សម្រាប់លក់ ផ្លាស់ប្តូរ ឬចាត់ចែងទៅឱ្យបុគ្គលណាម្នាក់ដើម្បីតម្លៃតបស្នងណាមួយ ឬផ្សេងពីនេះ។

១៧. **លក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ** សំដៅដល់លក្ខណវិនិច្ឆ័យ ដែលកំណត់ដោយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារដែលមានលក្ខណៈដាច់ខាតត្រូវបំពេញ។

១៨. **វិញ្ញាបនបត្រកម្ម** សំដៅដល់នីតិវិធីដែលអង្គភាពវិញ្ញាបនបត្រកម្មផ្លូវការ និងអង្គភាពដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ផ្តល់ការធានាជាលាយលក្ខណ៍អក្សរ ឬការធានាដែលមានតម្លៃសមមូលថាផលិតផល ម្ហូបអាហារឬប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារណាមួយ អនុលោមតាមលក្ខខណ្ឌតម្រូវ។

១៩. **វិញ្ញាបនបត្រ** សំដៅដល់ឯកសារភ្ជាប់ជាមួយនឹងម្ហូបអាហារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដូចជាវិញ្ញាបនបត្រសុវត្ថិភាពម្ហូបអាហារ វិញ្ញាបនបត្របសុព្យាបាល វិញ្ញាបនបត្រភូតគាមអនាម័យ វិញ្ញាបនបត្រវិភាគ ឬឯកសារផ្សេងទៀតដោយអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីម្ហូបអាហារ។

២០. **សារធាតុ** សំដៅដល់វត្ថុធាតុរឹង រាវ ឬឧស្ម័ន។

២១. **សារធាតុបន្ថែម** សំដៅដល់សារធាតុដែលជាទូទៅមិនអាចបរិភោគបានជាម្ហូបអាហារនិងជាធម្មតាមិនត្រូវបានប្រើប្រាស់ជាគ្រឿងផ្សំសម្រាប់ផលិតម្ហូបអាហារ ទោះបីជាសារធាតុបន្ថែមនោះមានឬមិនមានតម្លៃជាអាហារូបត្ថម្ភក្តី។ សារធាតុបន្ថែមទាំងនោះ ត្រូវបានគេប្រើប្រាស់ដោយចេតនាទៅក្នុងម្ហូបអាហារ ក្នុងគោលបំណងបច្ចេកវិទ្យា នៅក្នុងដំណើរការផលិតកម្ម កម្មន្តសាល ការរៀបចំ ប្រព្រឹត្តិកម្ម ការខ្ចប់ ការវេចខ្ចប់ ការដឹកជញ្ជូន ឬការស្តុកទុកម្ហូបអាហារទាំងនោះ ដើម្បីឱ្យមានលទ្ធផល ឬអាចរំពឹងទុកដោយសមហេតុផលថាមានលទ្ធផល (ដោយផ្ទាល់ឬប្រយោល) នៅក្នុងម្ហូបអាហារ ឬអនុផលរបស់ម្ហូបអាហារនោះ ឱ្យក្លាយទៅជាសមាសភាពរបស់ម្ហូបអាហារ ឬក៏អាចប៉ះពាល់ដល់ចរិតលក្ខណៈរបស់ម្ហូបអាហារ។ ប៉ុន្តែ សារធាតុបន្ថែមនេះ មិនរួមបញ្ចូលនូវសារធាតុចម្លង ឬជាសារធាតុដែលបន្ថែមក្នុងម្ហូបអាហារដើម្បីរក្សាឬបង្កើនគុណភាពអាហារូបត្ថម្ភនោះទេ។

២២. **សុវត្ថិភាពម្ហូបអាហារ** សំដៅដល់ការអនុវត្តដំណើរការធានាថា ម្ហូបអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ។

២៣. **សំបកវេចខ្ចប់** សំដៅដល់វត្ថុនានាដែលសម្រាប់ដាក់ឬវេចម្ហូបអាហារមួយផ្នែកឬទាំងមូល និងកន្ត្រក ភាជន៍ប្រអប់ ថាស ឬវត្ថុសម្រាប់ដាក់ផ្សេងទៀត ទោះមានឬមិនមានគម្របក្តី។

២៤. **ស្តង់ដារម្ហូបអាហារ** សំដៅដល់ស្តង់ដារផលិតផលជាក់លាក់និងស្តង់ដារទូទៅ ដោយរួមបញ្ចូលផងដែរនូវក្រមប្រតិបត្តិ និងគោលការណ៍ណែនាំ។ ស្តង់ដារម្ហូបអាហារនេះ អនុវត្តចំពោះម្ហូបអាហារទាំងអស់ ទោះត្រូវបានកែច្នៃ ឬកែច្នៃពាក់កណ្តាល ឬនៅស្រស់ ឆៅ សម្រាប់ចែកចាយដល់អ្នកប្រើប្រាស់។

២៥. **ស្ថានភាពគ្មានអនាម័យ** សំដៅដល់លក្ខខណ្ឌឬកាលៈទេសៈដែលអាចបង្កឱ្យមានការឆ្លង ឬនាំឱ្យមានការប៉ះពាល់ឬគ្រោះថ្នាក់ដល់សុខភាពរបស់អ្នកប្រើប្រាស់។

២៦. **ស្លាកសញ្ញា** សំដៅដល់ស្លាក យីហោ ម៉ាក ជារូបភាព ឬជាការពិពណ៌នាជាលាយលក្ខណ៍អក្សរ ជាការបោះពុម្ព ការបោះពុម្ពដោយប្រើស្ពិនស៊ីល ការគូសសម្គាល់ ធ្វើឱ្យក្រឡោត ឬរំលេចនៅលើ ឬភ្ជាប់ទៅនឹងវត្ថុសម្រាប់ដាក់ ឬសំបកវេចខ្ចប់ម្ហូបអាហារ។

២៧. **អ្នកនាំចេញ** សំដៅដល់បុគ្គលដែលជាកម្មសិទ្ធិករ អ្នកធ្វើទំនិញ អ្នកទទួលទំនិញ ភ្នាក់ងារ ឬឈ្មួញកណ្តាលដែលមានកម្មសិទ្ធិ ឬទទួលបានសិទ្ធិតាមវិធីណាមួយ ក្នុងការរក្សាទុក ឬមើលខុសត្រូវលើម្ហូបអាហារដែលនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

២៨. **អ្នកនាំចូល** សំដៅដល់បុគ្គលណាមួយ រួមមានអ្នកដែលជាកម្មសិទ្ធិករ អ្នកធ្វើទំនិញ អ្នកទទួលទំនិញ ភ្នាក់ងារ ឬឈ្មួញកណ្តាល ដែលមានកម្មសិទ្ធិ ឬទទួលបានសិទ្ធិតាមវិធីណាមួយក្នុងការរក្សាទុក ឬមើលខុសត្រូវលើម្ហូបអាហារ ដែលនឹងត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

២៩. **អាជីវកម្មម្ហូបអាហារ** សំដៅដល់សកម្មភាពធុរកិច្ចណាមួយដែលមិនមែនជាការធ្វើអាជីវកម្មម្ហូបអាហារ លក់តាមផ្លូវ ទោះជាខ្នាតតូចក្តី ដែលត្រូវធ្វើប្រតិបត្តិការនៅកន្លែងផលិតកម្ម កម្មន្តសាល ការរៀបចំ ប្រព្រឹត្តិកម្ម ការខ្ចប់ ការវេចខ្ចប់ ការដឹកជញ្ជូន ការលើកដាក់ ការបម្រើសេវា ការស្តុកទុក ឬការលក់ពាក់ព័ន្ធនឹងម្ហូបអាហារ ទោះក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ។

៣០. **សហគ្រាសករណ៍ម្ហូបអាហារ** សំដៅដល់សកម្មភាពណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការរៀបចំ ការរក្សាទុក និងការបម្រើសេវាម្ហូបអាហារនៅក្នុងទីតាំងម្ហូបអាហារ។

៣១. **បទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់ឯកសារដែលចែងអំពីចរិតលក្ខណៈផលិតផលឬដំណើរការពាក់ព័ន្ធ និងវិធីសាស្ត្រផលិតកម្ម ដោយរួមបញ្ចូលទាំងបញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន ដែលការអនុលោមមានលក្ខណៈបញ្ជា។ បទប្បញ្ញត្តិបច្ចេកទេស អាចរួមបញ្ចូលឬប្រើប្រាស់សម្រាប់តែការតម្រូវផ្នែក វាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។

៣២. **អនាម័យម្ហូបអាហារ** សំដៅដល់លក្ខខណ្ឌនិងវិធានការទាំងអស់ដែលចាំបាច់ធានាសុវត្ថិភាព និងភាពសមស្របនៃម្ហូបអាហារ នៅគ្រប់ដំណាក់កាលទាំងអស់នៃខ្សែចង្វាក់ម្ហូបអាហារ។

៣៣. **មន្ទីរពិសោធន៍ផ្លូវការ** សំដៅដល់មន្ទីរពិសោធន៍ដែលធ្វើតេស្តលើផលិតផលអាហារ គ្រឿងផ្សំ គំរូសំណាកកែច្នៃ និងគំរូសំណាកបរិស្ថានដែលពាក់ព័ន្ធសម្រាប់ការវិភាគរកប៉ារ៉ាម៉ែត្រ រូបសាស្ត្រ គីមី និងមីក្រូជីវសាស្ត្រ ហើយសំដៅដល់មន្ទីរពិសោធន៍រដ្ឋ ដែលគ្រប់គ្រងដោយក្រសួងឬស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវបានកំណត់លើមុខងារនិងវិសាលភាពជាក់លាក់។

៣៤. **មន្ទីរពិសោធន៍យោង** សំដៅដល់មន្ទីរពិសោធន៍ដែលធ្វើតេស្តលើផលិតផលអាហារ គ្រឿងផ្សំ គំរូសំណាកកែច្នៃ និងគំរូសំណាកបរិស្ថានដែលពាក់ព័ន្ធសម្រាប់ការវិភាគរកប៉ារ៉ាម៉ែត្រ រូបសាស្ត្រ គីមី និងមីក្រូជីវសាស្ត្រ ហើយសំដៅដល់មន្ទីរពិសោធន៍រដ្ឋឬឯកជនដែលមានជំនាញឯកទេសវិភាគតាមវិសាលភាពដែលត្រូវបានកំណត់ជាក់លាក់និងទទួលបានការវាយតម្លៃពីស្ថាប័នទទួលស្គាល់។

៣៥. **ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពម្ហូបអាហារ** សំដៅដល់ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/៤៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការ ៨៧ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍ ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ជា ម៉ូរ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-ឯកឧត្តម **ឱក តារារិទ្ធិ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-ឯកឧត្តម **ជា សៃ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-ឯកឧត្តម **ប្រាក់ ច័ន្ទតារា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥-ឯកឧត្តម **គង់ សុលីដា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦-ឯកឧត្តម **សុខ តុងហាប់** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |
| ៧-ឯកឧត្តម **ថុក សុខុម** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |
| ៨-ឯកឧត្តម **សុខ សុគុណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |
| ៩-ឯកឧត្តម **ជា ចាន់ហេង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |
| ១០-ឯកឧត្តម **គង់ សុតារត្ន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | |
|---|---|---|
| ១១-ឯកឧត្តម **ទ៉ាត់ ចំរើន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១២-ឯកឧត្តម **ណោប សាមុត** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៣-លោក **យិន ស៊ីផេង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៤-លោក **សំ សេង** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៥-លោក **សេង ភក្តី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៦-លោកស្រី **ផ្កា ស៊ីណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៧-លោក **គឹម ប៊ុនណារ៉ា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៨-លោកស្រី **រស់ សូលិកា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ១៩-លោក **សេង សិទ្ធិអុណា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២០-លោក **សំ សុភី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២១-ឯកឧត្តម **ម៉ម ទាសនា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២២-លោក **ខិន សុមិមាន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២៣-លោក **ឆឹម ទេពចន្ទា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២៤-លោក **នុត សារ៉ែន** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២៥-លោក **គីម រ៉ាវី** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២៦-លោក **ដុង សុខេមរៈ** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មកជា ថ្នាក់លេខ ៥ |
| ២៧-លោកជំទាវ **ហ៊ុន ដានី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២៨-ឯកឧត្តម **សូ វិសុទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ២៩-ឯកឧត្តម **ជា កុសល** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣០-ឯកឧត្តម **ហាឡុ សណ្ដាប់** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣១-លោកជំទាវ **ប៉ូច វរលក្ខណ៍** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣២-ឯកឧត្តម **ហ៊ាយ តីរម្យ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៣-ឯកឧត្តម **ប៊ូ ចន្ទសិរី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៤-ឯកឧត្តម **ហោង សុដានី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៥-ឯកឧត្តម **លីវ វណ្ណហោង** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៦-ឯកឧត្តម **ប្រឡឹង សុមេធា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៧-ឯកឧត្តម **ផ្លុង ធឿន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៨-លោក **ឡាង សុលីណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៣៩-លោក **ឡោ ឆូរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤០-លោក **ឈឹម សុខជិន** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤១-លោកស្រី **ដោក ស៊ីណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤២-លោក **ធឹម ថារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៣-លោក **ធែន រតនា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៤-លោក **សុខ វណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៥-លោក **ជា ច័ន្ទដារី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៦-លោក **កែន សុភី** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៧-លោក **ឈុន ណារាក់** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ៤៨-លោក **ម៉ម ម៉ានីរដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៤៩-លោក **ម៉ម គុណាវុឌ្ឍ** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
| ៥០-លោក **សេង ខា** | ពីវរមន្ត្រី ថ្នាក់លេខ ១ | មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦ |
**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ជាណាន** (WANG JIANAN) ជនជាតិចិន សញ្ជាតិចិន កើតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ នៅខេត្តចឺជាំង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ពរក.២២០៣.៣០១

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/៣៧០០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ហុកខែនបឺរី ដាន់ញ៉ែល អូលីវើ** (HOCKENBERRY DANIEL OLIVER) ជនជាតិម៉ាដាហ្គាស្កា សញ្ជាតិម៉ាដាហ្គាស្កា កើតនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩០ នៅខេត្តម៉ុនហ្គូម៉ារី សាធារណរដ្ឋម៉ាដាហ្គាស្កា ដោយប្តូរឈ្មោះជា **មាស ណាវ៉ាត្រា** (MEAS NAVATRA) ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ជំនួសនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/ ៣០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ចំពោះ

ឯកឧត្តមឧត្តមសេនីយ៍ឯក **មួង ឃីម**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ការល.៥៤០៣.៣០៣

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/៣០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពោធិភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ថ្នូវ**

គ្រឿងឥស្សរិយយស **ជាតូបការ**

ចំពោះ

១-លោក LIM CHAI LOON

២-លោក **ហ្គុយ ឆាយ**

៣-លោកស្រី **សៀង ស៊ីពោធិ**

៤-លោក **ហេង ឆួន**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២
**ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់**
**ប្រមុខរដ្ឋស្តីទី**

[illegible].៤៤០៣-៣០៤

ហ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/៣០៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

ចំពោះ

| | |
|---|---|
| ១-ឧត្តមសេនីយ៍ត្រី **អ៊ិន ហៀប** | អត្តលេខ ០០៣៤២៣ |
| ២-ឧត្តមសេនីយ៍ត្រី **សែម រ័ត្ននាង** | អត្តលេខ ០៣៦៦០២ |
| ៣-វរសេនីយ៍ឯក **រស់ សុធា** | អត្តលេខ ០១៦៤៦៩ |
| ៤-វរសេនីយ៍ទោ **សរ សុជាតិ** | អត្តលេខ ០៣១៨៣២ |
| ៥-វរសេនីយ៍ទោ **សែម រ៉ាឌុទ្ធ** | អត្តលេខ ២៣៩៤០១ |
| ៦-វរសេនីយ៍ទោ **ឌិត នីន** | អត្តលេខ ០៥៨៣៥២ |
| ៧-វរសេនីយ៍ត្រី **ហេង ណារិន** | អត្តលេខ ០៩៣៧៦១ |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២
**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣៣៧.៤៤០៣.៣០៥

ហ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣២២/៣០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ដល់សប្បុរសជន ២៧រូបះ

ក-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ស៊ិន អេរីក | ៦- | លោក | ពីង ប៊ុនលាង |
| ២- | លោក | ឈូ គីមឃុន | ៧- | លោក | មៀង ធុល |
| ៣- | លោកស្រី | អ៊ាក ច័ន្ទរស្មី | ៨- | លោក | យុយ ហេង |
| ៤- | លោក | ម៉ុច ពេជ្រ | ៩- | លោក | ទី ឌី |
| ៥- | លោក | ណាង សារី | | | |

ខ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | ព្រះគ្រូធម្មានុវត្តន៍ | ដែម សុផានណា | ៥- | លោកស្រី | ម៉ា ម៉ុកយ៉ុង |
| ២- | លោក | សាម ណាល់ | ៦- | លោក | អាន វាសនា |
| ៣- | លោក | អ៊ុង វាសនា | ៧- | ឧបាសក | ម៉ន ចែម |
| ៤- | លោក | ហ៊ាង ហៀក | ៨- | ឧបាសិកា | គង់ វៃ |

គ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | ទីវ សំណាង | ៣- | លោក | អៀ ម៉េងគួង |
| ២- | លោក | គង់ សារិទ្ធិ | | | |

ឃ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | វ៉ាន់ ឡឿន | ៥- | លោក | អ៊ុន ខ្នា |
| ២- | ឧបាសិកា | អ៊ុក ជាតិ | ៦- | ឧបាសិកា | សុខ អ៊ីម |
| ៣- | ឧបាសិកា | ណាម មៅ | ៧- | លោក | ទូច សារ៉េត |
| ៤- | លោកស្រី | ស៊ិន សុខលាន | | | |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាក់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ហ.ជ.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣រស.៤៤០៣.៣០៦

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

នស/រកត/០៣២២/៣០៥

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១១៣រូប៖

ក-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សៅ វណ្ណសិរីវុទ្ធ** | ៧-លោក | **អ៊ុំ សាវី** |
| ២-ឯកឧត្តម | **សួន សេរី** | ៨-លោក | **សេង ស៊ិនណារុន** |
| ៣-ឯកឧត្តម | **ហៃម វីរៈ** | ៩-លោក | **ម៉េង សុធី** |
| ៤-លោក | **អ៊ីវ សុខសាន្ត** | ១០-លោក | **សៅ កុសល់** |
| ៥-លោក | **ប៉ិច សុវណ្ណ** | ១១-លោក | **ពី ស៊ា** |
| ៦-លោក | **មៅ មិនា** | ១២-លោក | **បៃន បុល្លីណា** |

ខ-គ្រឿងឥស្សរិយយស**សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ហ៊ីម អូន** | ១៦-លោក | **ទិត សារ៉ា** |
| ២-លោក | **ហ៊ល ដារុន** | ១៧-លោក | **ង៉ែត ភូ** |
| ៣-លោក | **មៅ ដារុថ** | ១៨-លោក | **ស៊ុំ សុខុម** |
| ៤-លោកស្រី | **ភ៉ សុផល** | ១៩-បណ្ឌិត | **លាង សុផា** |
| ៥-លោក | **ឈៀង តុលា** | ២០-លោក | **កៅ មុនីរិទ្ធ** |
| ៦-លោក | **ស៊ឹម ថាវីរៈ** | ២១-លោកស្រី | **ឈី សាវរី** |
| ៧-លោក | **រុន សុផាន់ណារ៉ា** | ២២-លោកស្រី | **ស្រេង ផុននី** |
| ៨-លោកស្រី | **ហេង គីមស្រៀង** | ២៣-លោក | **ថោ ឡូ** |
| ៩-លោក | **ឈ បៀងគង់** | ២៤-លោក | **សោម សុវណ្ណ** |
| ១០-លោក | **ណុប សារិន** | ២៥-លោក | **ហង់ជួន ចំរ៉ុង** |
| ១១-លោក | **មាស ហ្សានី** | ២៦-លោក | **ម៉ែន សុទ្ធី** |
| ១២-លោក | **ព្រំ វិច** | ២៧-លោក | **សុខ ប៉ុណ្ណៈកុសល** |
| ១៣-លោក | **ងិន នី** | ២៨-លោក | **រុន វិសិទ្ធ** |
| ១៤-លោក | **ទិត ប៊ុនឈឿន** | ២៩-លោក | **នេត សុទ្ធា** |
| ១៥-លោក | **នុព សុធា** | ៣០-លោក | **ភួន ចេក** |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១-លោក | ឈាង ជាន | ៦-លោក | ពីង ទិត |
| ២-លោកស្រី | កៅ សុជីវី | ៧-លោក | សេង ម៉េង |
| ៣-លោកស្រី | សូ ស្រីមុំ | ៨-លោក | ពៅ សារឿន |
| ៤-លោក | សោ សុដ្ឋាដេត | ៩-លោក | ឃី ធី |
| ៥-លោក | ភី រាវិន | | |

ឃ-គ្រឿងឥស្សរិយយស**សុវត្ថារា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១-លោក | រាជ សម្បត្តិ | ១៩-លោក | ទូច ប៊ុនធឿង |
| ២-លោកស្រី | ប៉ុល រក្ខិតា | ២០-លោក | ហាម សារាវុធ |
| ៣-លោក | ប៉ែន ប៊ុនធឿន | ២១-លោក | សួន ផល្លា |
| ៤-លោកស្រី | សរ រីណេ | ២២-លោក | ឡាវ សេដ្ឋាផល |
| ៥-លោក | ស៊ីម ធី | ២៣-លោក | សុខ ស្រ៊ុន |
| ៦-លោក | ណយ សុភិរម្យ | ២៤-លោកស្រី | ជា ស៊ីណា |
| ៧-លោកស្រី | ឡូ សុខា | ២៥-លោក | ចាប ចាន់ថុល |
| ៨-លោក | ជួន សារ៉ា | ២៦-លោក | សៀង ស្រ៊ុន |
| ៩-លោកស្រី | គាវ ដាវី | ២៧-លោកស្រី | ស ស៊ីមលីន |
| ១០-លោក | ចក់ ស៊ីគៀង | ២៨-លោក | លិន សូពៅ |
| ១១-លោក | សោម ប៊ុណ្ណា | ២៩-លោក | បួយ រតនា |
| ១២-លោក | ហ៊ុន សារ៉ាត់ | ៣០-លោកស្រី | ថាច់ ផាន់ណាឌី |
| ១៣-លោក | ឈួន វុឌ្ឍី | ៣១-លោក | ឡៅ សុភា |
| ១៤-លោកស្រី | ហ៊ីង សារិន | ៣២-លោក | ជួប សុខន |
| ១៥-លោក | រឿង សុផាត | ៣៣-លោក | គង់ ជា |
| ១៦-លោក | សេង សារ៉ាត់ | ៣៤-លោក | ឈ ប៊ុនលី |
| ១៧-លោក | លន់ ទីណា | ៣៥-លោក | ឌី សំអាត |
| ១៨-លោក | កែប ង៉ែត | ៣៦-លោកស្រី | ឆាយ ណុច |

ង-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១-លោក | កើត កត្តិនាថ | ៣-បណ្ឌិត | ម៉ែន សារុម |
| ២-លោក | ស្រ៊ុន សុខុម | ៤-លោក | ទី ចាន់ណា |

ច-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ឃី កុសល | ៤-លោកស្រី | ម៉ិល ច័ន្ទទេវី |
| ២-ឯកឧត្តម | សៀក ឡេង | ៥-លោកស្រី | ហង់ ណាវី |
| ៣-លោក | សំ នោមសង្ហា | ៦-លោកស្រី | គយ សុខុម |

ឆ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ធិន ឆាយ** | ៩-លោកស្រី | **ស៊ឹម សុចិន្តា** |
| ២-លោកបណ្ឌិត | **កែ មុន្នីវុធ** | ១០-លោកស្រី | **ចាន់ វ៉ារីយ៉ា** |
| ៣លោក | **ទី សុង** | ១១-លោកស្រី | **ជា សុម៉ាលី** |
| ៤-លោក | **ទុំ នីរ៉ូ** | ១២-លោកស្រី | **វ៉ា ផាវី** |
| ៥-លោក | **ប៉ាង វណ្ណាសេដ្ឋ** | ១៣-លោក | **ហេង សុថារិទ្ធ** |
| ៦-លោក | **យឹម ណន** | ១៤-លោក | **ហាំង ណាភ** |
| ៧-លោក | **ផល មុនី** | ១៥-លោក | **ងួន សុគន្ធ** |
| ៨-លោក | **លឹម គឹមឡុង** | ១៦-លោក | **ខូវ កេងឃាង** |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧-៤៤០៣.៣០៧

ហ.ស.

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/ ០៣២២ / ៣០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៤ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ ស្តីពីការជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **លីម ម៉ិនហុក** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នីតិកាលទី៤។

**មាត្រា២ :** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២២

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨២ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកាត់ឆ្វៃដីទំហំ ៣៧៥ ហិកតា ៩៣ អា និង ៤៧ សង់ទីអា ចេញពីដែនគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ ប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចព្រៅ ស្ថិតក្នុងភូមិកាឡៀង ឃុំល្បាំង១ ស្រុកលំផាត់ ខេត្តរតនគិរី ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ ..**

កាត់ផ្ទៃដីទំហំ ៣៧៥ ហិកតា ៩៣ អា និង ៤៧ សង់ទីអា ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចព្រៅ ស្ថិតក្នុងភូមិកាទៀង ឃុំល្បាំង១ ស្រុកលំផាត់ ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២ ..**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ខាងលើ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣ ..**

ផ្តល់សិទ្ធិជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចព្រៅ ១សហគមន៍ មានចំនួន ៦៩គ្រួសារ លើក្បាលដីសរុប ៤០ក្បាលដី ដែលរួមមាន ដីលំនៅឋាន ៥ក្បាលដី និងដីកសិកម្ម ៣៥ក្បាលដី ស្ថិតក្នុងភូមិកាទៀង ឃុំល្បាំង១ ស្រុកលំផាត់ ខេត្តរតនគិរី។

**មាត្រា៤ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ រោច ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ



ម៉ា

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី២
## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានមុខងារនិងភារកិច្ចដូចតទៅ៖

- ការរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលដៅ ទិសដៅ កម្មវិធី យន្តការក្នុងការគ្រប់គ្រង ដឹកនាំ ចាត់ចែង ផ្តល់សេវាគាំពារដល់មុខសញ្ញាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កសាងនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងផែនការពាក់ព័ន្ធនឹងវិស័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របតាមលិខិតបទដ្ឋានជាតិនិងអន្តរជាតិ
- សិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រលើផ្នែកសង្គមកិច្ច
- គ្រប់គ្រងការងារសុំកូនក្នុងប្រទេសនិងអន្តរប្រទេស
- ដឹកនាំ គ្រប់គ្រង និងសហការជាមួយដៃគូ អង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើសកម្មភាព លើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំបង្កើតយន្តការជំរុញបំផុសការចូលរួមសកម្មភាពការងារសង្គមកិច្ច សាមគ្គីធម៌សង្គម លើកទឹកចិត្តដល់ក្រុមហ៊ុន សហគ្រាសរដ្ឋ ឯកជន អង្គការមនុស្សធម៌ ដៃគូអភិវឌ្ឍ សហគមន៍ និង មហាជនដែលបានចូលរួមសកម្មភាពដើម្បីសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានរចនាសម្ព័ន្ធដូចតទៅ៖

**ក-អង្គភាពថ្នាក់ជាតិ**

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច
- អគ្គនាយកដ្ឋានសេវាសង្គមកិច្ច

- អគ្គនាយកដ្ឋានស្តារសម្បទា
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- វិទ្យាស្ថានជាតិសង្គមកិច្ច
- មណ្ឌលយុវនីតិសម្បទា
- មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

**ខ- គ្រឹះស្ថានសាធារណៈរដ្ឋបាល**

គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ-មណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈមណ្ឌលតំបន់**

មណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈមណ្ឌលតំបន់ ដែលមានទីតាំងស្ថិតនៅតាមបណ្តារាជធានី ខេត្ត។

**ឃ-អង្គភាពថ្នាក់ក្រោមជាតិ**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។

**មាត្រា៥ .-**

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការអនុលោមតាម បទប្បញ្ញត្តិជាធរមាន។

អង្គភាពថ្នាក់ស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន មានឋានៈនិងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋានជាជំនួយការអនុលោមតាម បទប្បញ្ញត្តិជាធរមាន។

មណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈមណ្ឌលតំបន់ ជាអង្គភាពថ្នាក់ជាតិចំណុះក្រសួងផ្ទាល់ដែលមាន ទីតាំងស្ថិតនៅតាមបណ្តារាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជា ជំនួយការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ប្រធាន និងអនុប្រធានមណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈ មណ្ឌលតំបន់ ត្រូវតែងតាំងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គភាពថ្នាក់ក្រោមជាតិ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានឬអង្គភាពប្រហាក់ប្រហែល និងអង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧ .-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់ដោយអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា៨ .-**

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការ រដ្ឋបាល បុគ្គលិក ពិធីការ ផែនការ បូកសរុប ហិរញ្ញវត្ថុ គណនេយ្យ ទ្រព្យសម្បត្តិរដ្ឋ កិច្ចសហប្រតិបត្តិការ ទំនាក់ទំនងសាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងសម្របសម្រួលការងារទូទៅជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល។

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ មាននាយកដ្ឋានចំនួន៤(បួន)ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី។

**មាត្រា៩ .-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ពិនិត្យ និងចរាចរលិខិតឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួងនិងស្ថាប័ននានាដែលផ្ញើមកក្រសួង និងលិខិតផ្ទៃក្នុង
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់បណ្តានាយកដ្ឋាននិងអង្គភាពនានាចំណុះក្រសួង
- គ្រប់គ្រងនិងចរាចរឯកសាររបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- ណែនាំរបៀបរបបធ្វើការងាររដ្ឋបាលដល់អង្គភាពក្រោមឱវាទក្រសួង
- ធ្វើរបាយការណ៍ការងារនិងកំណត់ហេតុផ្សេងៗរបស់ថ្នាក់ដឹកនាំក្រសួង
- គ្រប់គ្រងផ្នែករដ្ឋបាលចំពោះមន្ត្រីរាជការរបស់ក្រសួង
- រៀបចំរាល់លិខិតរដ្ឋបាលពាក់ព័ន្ធបុគ្គលិករបស់ក្រសួងសម្រាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីតំណែងឯកទេសនិងធនធានមនុស្សរបស់ក្រសួង
- ការងារបណ្តុះបណ្តាល វិក្រឹតការមន្ត្រីរាជការរបស់ក្រសួង



ﾀ ﾚ

- រៀបចំ គ្រប់គ្រង ស្ថិតិ និងឯកសារមន្ត្រីរាជការ
- វាយតម្លៃ ដំឡើងឋានៈ ផ្តល់គ្រឿងឥស្សរិយយស លើកទឹកចិត្តដល់អង្គភាពឬបុគ្គលដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំបៀវត្ស ប្រាក់កម្រៃ និងរបបឧបត្ថម្ភគោលនយោបាយសម្រាប់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង។

**មាត្រា១០.-**

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងដឹកនាំនិងចាត់ចែងការងារផែនការស្ថិតិ សរុប
- កសាងផែនការយុទ្ធសាស្ត្រ និងផែនការរយៈពេលខ្លី រយៈពេលវែងរបស់ក្រសួង
- សិក្សារៀបចំទិន្នន័យ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាពការងាររបស់ក្រសួង
- ប្រមូល ចងក្រង និងរៀបចំស្ថិតិមុខសញ្ញាដែលក្រសួងទទួលបន្ទុក
- សិក្សាស្ថិតិនិងរៀបចំទិសដៅអនាគតស្តីពីវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សហការជាមួយនាយកដ្ឋាននានារៀបចំសេចក្តីណែនាំ សារាចរ លិខិតបទដ្ឋាននានា និងផែនការអភិវឌ្ឍន៍របស់ក្រសួង។
- ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ក្រសួង
- ពិនិត្យវាយតម្លៃបរិមាណ គុណភាព និងសមិទ្ធផលរបស់ក្រសួង
- រៀបចំ និងណែនាំពីរបៀបរបបរាយការណ៍ របស់អង្គភាពក្រោមឱវាទក្រសួង
- ពិនិត្យ តាមដាន និងប្រមូលព័ត៌មានលើមុខសញ្ញាដែលក្រសួងទទួលបន្ទុក
- ផ្សព្វផ្សាយលទ្ធផលការងារនិងសកម្មភាពថ្នាក់ដឹកនាំ។

**មាត្រា១១.-**

នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារហិរញ្ញវត្ថុនិងផ្គត់ផ្គង់ជូនក្រសួង
- ប្រមូលចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋ
- ដឹកនាំសម្របសម្រួលជាមួយបណ្តាអង្គភាពក្រោមឱវាទក្រសួងក្នុងការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិលនិងថវិកាប្រចាំឆ្នាំ
- កសាងនិងពង្រឹងសមត្ថភាពមន្ត្រីជំនាញដែលពាក់ព័ន្ធនឹងការងារគណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ
- តាមដានរាល់សកម្មភាពចំណូលចំណាយនិងធ្វើរបាយការណ៍បូកសរុបស្តីពីស្ថានភាពចំណូលចំណាយថវិកាគ្រប់ប្រភេទរបស់ក្រសួង
- ប្រមូលផ្តុំនិងសម្របសម្រួលរាល់ការចំណាយរបស់ក្រសួង
- អនុវត្តការងារលទ្ធកម្មសាធារណៈ

- សហការនិងសម្របសម្រួលជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុក្នុងការងារត្រួតពិនិត្យចំណូលចំណាយថវិការបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង
- គ្រប់គ្រងសន្និធិ និងផ្គត់ផ្គង់
- កាន់កាប់បញ្ជីគណនេយ្យ ។

**មាត្រា១២.-**

នាយកដ្ឋានសហប្រតិបត្តិការមានភារកិច្ចដូចតទៅ៖

- ចូលរួមសម្របសម្រួលនិងសហប្រតិបត្តិការជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាល និងជាមួយអង្គភាពជំនាញដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច
- រៀបចំផែនការនិងតាមដានការអនុវត្តផែនការសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយស្ថាប័នជាតិនិងអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច រៀបចំផែនការនិងតាមដានការអនុវត្តការងារអាស៊ានដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងជាមួយលេខាធិការដ្ឋានអាស៊ាន។

## ជំពូកទី៥

## អគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច

**មាត្រា១៣.-**

អគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ច មានតួនាទីនិងភារកិច្ច ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួង។

អគ្គនាយកដ្ឋានគោលនយោបាយសង្គមកិច្ចមាននាយកដ្ឋានចំណុះចំនួន៣(បី) ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី។

**មាត្រា១៤.-**

នាយកដ្ឋានអភិវឌ្ឍន៍គោលនយោបាយ មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ ទំនើបកម្ម ពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច
- សិក្សាស្រាវជ្រាវ លើកសំណើ និងវិភាគមុខងារស្ថាប័ន អង្គភាពដែលមានតួនាទីភារកិច្ចពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច
- រៀបចំ កែលម្អ និងជំរុញការអនុវត្តគោលនយោបាយស្តីពីវិស័យសង្គមកិច្ច
- សិក្សានិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្នុងការរៀបចំនិងចងក្រងគោលនយោបាយ សេចក្តីណែនាំ និងការដាក់ឱ្យអនុវត្តនៃវិស័យសង្គមកិច្ច
- សិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រលើផ្នែកសេវាសង្គមកិច្ចដើម្បីឱ្យការរៀបចំសេវាផ្នែកវិស័យសង្គមកិច្ចឆ្លើយតបទៅនឹងបច្ចុប្បន្នភាពនៃសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេស
- បង្កើតគំរូឬស្តង់ដានៃការផ្តល់សេវាវិស័យសង្គមកិច្ច
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយដែលឆ្លើយតបតាមតម្រូវការជាក់ស្តែង

- បង្កើតនិងអនុវត្តគោលនយោបាយថ្មី ដើម្បីឱ្យការផ្តល់សេវាឆ្លើយតបតាមតម្រូវការនិងសមស្រប តាមស្ថានភាពជាក់ស្តែង ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការងារសង្គមកិច្ច
- សិក្សាស្រាវជ្រាវមុខងារសង្គមកិច្ចស្របតាមបរិបទសង្គម សេដ្ឋកិច្ច បរិស្ថាន និងស្ថានភាព សកលលោក។

**មាត្រា១៥ .-**

នាយកដ្ឋានពិនិត្យ តាមដាន និងគ្រប់គ្រងទិន្នន័យមានភារកិច្ចដូចតទៅ៖

- រៀបចំបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនៃការតាមដាន ការអនុវត្តគោលនយោបាយ
- លើកសំណើអំពីការវាយតម្លៃនៃការអនុវត្តគោលនយោបាយនានានិងកំណត់អំពីអាទិភាពនៃ ផែនការ សកម្មភាព ដើម្បីធ្វើបច្ចុប្បន្នកម្មស្តង់ដាប្រសិទ្ធភាពយន្តការអនុវត្ត
- ប្រមូលសមិទ្ធផលនិងវិភាគលើលទ្ធផលជាក់ស្តែងដែលទទួលបានពីការអនុវត្តគោលនយោបាយ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយក្រសួងនិងរាជរដ្ឋាភិបាល
- លើកសំណើសុំការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ដើម្បីទទួលបានធាតុ ចូលក្នុងការរៀបចំអនុសាសន៍កែប្រែសូចនាករ រចនាសម្ព័ន្ធ និងអនុវត្តការងារបន្ត
- ផ្តល់អនុសាសន៍ដើម្បីធ្វើបច្ចុប្បន្នកម្មគោលនយោបាយឱ្យមានសង្គតិភាពជាមួយស្ថានភាព សេដ្ឋកិច្ច នយោបាយ សង្គម និងបរិបទតំបន់និងពិភពលោក
- ចុះពិនិត្យ តាមដាន និងវាយតម្លៃ ព្រមទាំងវិភាគការអនុវត្តគោលនយោបាយដែលបានដាក់ ចេញតាមរាជធានី ខេត្តជាប្រចាំ
- រៀបចំគោលការណ៍ណែនាំ ទម្រង់របាយការណ៍ ទម្រង់ប្រមូលទិន្នន័យ
- អភិវឌ្ឍសមត្ថភាព ដើម្បីធានាការពិនិត្យ តាមដាន និងវាយតម្លៃ ព្រមទាំងវិភាគការអនុវត្ត គោលនយោបាយប្រកបដោយប្រសិទ្ធភាព
- ប្រមូល ចងក្រង គ្រប់គ្រងទិន្នន័យលើវិស័យសង្គមកិច្ច
- គ្រប់គ្រង រក្សា និងការពារសុវត្ថិភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងបរិក្ខារបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធ នឹងវិស័យសង្គមកិច្ច។

**មាត្រា១៦ .-**

នាយកដ្ឋាននីតិកម្មនិងដោះស្រាយវិវាទសង្គមកិច្ចមានភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ លើកសំណើរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតទាក់ទងនឹងវិស័យ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សម្របសម្រួលនិងចូលរួមជាមួយអង្គភាពពាក់ព័ន្ធលើការងារកសាងសេចក្តីព្រាងច្បាប់និងលិខិត បទដ្ឋានគតិយុត្តផ្សេងទៀត និងគោលនយោបាយលើវិស័យពាក់ព័ន្ធនានា
- ពិនិត្យ ផ្តល់យោបល់ កែសម្រួលលើទម្រង់និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋាន គតិយុត្តផ្សេងទៀត និងគោលនយោបាយដែលរៀបចំដោយអង្គភាពជំនាញនិងស្ថាប័នពាក់ព័ន្ធ
- ផ្តល់យោបល់និងផ្តល់ការប្រឹក្សាផ្នែកច្បាប់និងនីតិវិធីជូនអង្គភាពក្រោមឱវាទក្រសួង
- ដោះស្រាយវិវាទមុខងារដែលត្រួតសមត្ថកិច្ចគ្នានិងសម្របសម្រួល
- ដោះស្រាយវិវាទសង្គមកិច្ចពាក់ព័ន្ធ។

## ជំពូកទី៦
## អគ្គនាយកដ្ឋានសេវាសង្គមកិច្ច

**មាត្រា១៧.-**

អគ្គនាយកដ្ឋានសេវាសង្គមកិច្ច មានតួនាទីនិងភារកិច្ចផ្តល់សេវាសង្គមកិច្ចទូទៅក្នុងគោលបំណងគាំពារគុណភាពជីវិត សេចក្តីថ្លៃថ្នូរ ការធ្វើឱ្យប្រសើរឡើងនៃស្ថានភាពរស់នៅ បង្ការ ទប់ស្កាត់បញ្ហាប្រឈមនានារបស់ជនរងគ្រោះ ជនងាយរងគ្រោះតាមរយៈសកម្មភាពនិងអន្តរាគមន៍កម្រិតបុគ្គល គ្រួសារ សហគមន៍ សេដ្ឋកិច្ច សង្គមនិងនយោបាយ។

អគ្គនាយកដ្ឋានសេវាសង្គមកិច្ច មាននាយកដ្ឋានចំណុះចំនួន៤(បួន)ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី។

**មាត្រា១៨.-**

នាយកដ្ឋានមនុស្សចាស់និងអតីតយុទ្ធជនមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងវិស័យសុខុមាលភាពមនុស្សចាស់ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការ
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងមនុស្សវ័យចាស់ អតីតយុទ្ធជន អតីតមន្ត្រីរាជការ
- រៀបចំកម្មវិធីអភិវឌ្ឍន៍សមាគមមនុស្សវ័យចាស់ អតីតយុទ្ធជន អតីតមន្ត្រីរាជការ និងលើកកម្ពស់ការគាំពារមនុស្សវ័យចាស់ អតីតយុទ្ធជន អតីតមន្ត្រីរាជការនៅតាមគ្រួសារ សហគមន៍ និងទីអារាម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យបង្កើតមណ្ឌល មជ្ឈមណ្ឌលសហគមន៍ ថែទាំមនុស្សវ័យចាស់ឯកជនមិនប្រើប្រាស់ថវិកាជាតិ
- ជំរុញលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការស្មគ្រចិត្តនានា ដើម្បីបង្កើតនិងពង្រីកឱកាសឱ្យមនុស្សវ័យចាស់ អតីតយុទ្ធជន អតីតមន្ត្រីរាជការអាចពឹងផ្អែកខ្លួនឯងបាន
- សិក្សាអំពីគំរូថែទាំមនុស្សវ័យចាស់និងលើកទឹកចិត្តដល់បុត្រធីតា សាច់ញាតិ ក្រុមគ្រួសារដែលមើលថែទាំមនុស្សវ័យចាស់របស់ពួកគេ
- សម្របសម្រួលធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីដឆ្នាំ២០០២ និងឆ្លើយតបទៅនឹងតម្រូវការនិងកំណើនប្រជាជនជាក់ស្តែងនាពេលបច្ចុប្បន្ននិងអនាគត
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការពិនិត្យ តាមដាន និងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការ សមាគម ដើម្បីផ្តល់សេវាទ្រទ្រង់ជីវភាព ព្យាបាលជំងឺ ជួយអ្នកនៅក្នុងបន្ទុក តម្រូវការផ្សេងៗ និងសាងសង់លំនៅឋានជូនអតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិលនិងគ្រួសារ។

**មាត្រា១៩ .-**

នាយកដ្ឋានកិច្ចការពារកុមារមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចការពារកុមារ
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ
- ពង្រឹងពង្រីកប្រព័ន្ធកិច្ចការពារកុមារតាមរយៈការបង្ការ ការការពារ និងផ្តល់សេវាដល់កុមាររងគ្រោះនិងងាយរងគ្រោះ
- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាថែទាំជំនួសចំពោះកុមារកំព្រាគ្មានទីពឹង កុមារក្រីក្រ កុមាររងគ្រោះនិងងាយរងគ្រោះ
- បង្កើនប្រសិទ្ធភាពនិងសមត្ថភាពអ្នកផ្តល់សេវាសង្គមផ្នែកកុមារអំពីកិច្ចការពារកុមារ
- សម្របសម្រួលគាំទ្របច្ចេកទេសនិងត្រួតពិនិត្យការអនុវត្តមុខងារការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល និងការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅថ្នាក់ក្រោមជាតិ
- ជំរុញនិងត្រួតពិនិត្យប្រសិទ្ធភាពនៃការផ្តល់សេវាជួយគាំពារកុមារ ការរក្សាទុក ការថែទាំ ការបង្រួបបង្រួមឬធ្វើសមាហរណកម្មកុមារឱ្យទៅរស់នៅជុំគ្រួសារនិងសហគមន៍
- ជំរុញនិងអនុវត្តផែនការអចិន្ត្រៃយ៍សម្រាប់ករណីកុមាររងគ្រោះនិងងាយរងគ្រោះដែលត្រូវការការថែទាំជាអចិន្ត្រៃយ៍
- លើកកម្ពស់ចំណេះដឹងអំពីការងារកុមារ ការគ្រប់គ្រងករណី និងនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារដល់អ្នកពាក់ព័ន្ធ
- បណ្តុះបណ្តាល និងផ្តល់វិញ្ញាបនបត្របញ្ជាក់អំពីសុវត្ថិភាពកុមារដល់អង្គការអនុវត្តការថែទាំកុមារនៅតាមកន្លែងថែទាំ
- គ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូនតាមម្តាយជាប់ពន្ធនាគារដែលមានអាយុចាប់ពី៣ឆ្នាំឡើង បើគ្មានសាច់ញាតិឬអាណាព្យាបាលទទួលខុសត្រូវ
- រៀបចំផែនការសកម្មភាព ផែនការថវិកាប្រចាំឆ្នាំ កៀរគរធនធានពីអង្គការដៃគូ និងវិស័យឯកជនដើម្បីគាំទ្រសុខុមាលភាពកុមារ។

**មាត្រា២០ .-**

នាយកដ្ឋានកិច្ចការគ្រួសារមានភារកិច្ចដូចតទៅ៖

- កសាងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកិច្ចការគ្រួសារ
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងកិច្ចការគ្រួសារ
- រៀបចំយន្តការដើម្បីឱ្យគ្រួសារក្រីក្រមានជម្រករស់នៅសមរម្យ
- ផ្តល់សេវាគាំពារគ្រួសារដោយបង្កើតមុខរបរ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗ អប់រំគ្រួសារបែបវិជ្ជមាន លើកកម្ពស់តម្លៃស្ត្រី អប់រំសីលធម៌សង្គមគ្រួសារ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ



អ៤

- រៀបចំលក្ខណវិនិច្ឆ័យ កំណត់អត្តសញ្ញាណជនក្រីក្រ និងផែនការសកម្មភាពដើម្បីគាំទ្រនិងចូលរួមអនុវត្តកម្មវិធីគាំពារគ្រួសារក្រីក្រនិងក្រុមគ្រួសារងាយរងគ្រោះ
- អនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ក្រីក្រនិងបង្កើតសកម្មភាពសង្គហសង្គ្រោះជួយដល់ជនក្រីក្រដើម្បីទប់ស្កាត់ទុគ៌តភាពនិងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន
- រៀបចំយន្តការផ្តល់សេវាដើម្បីគាំទ្រកម្មវិធីជួយដល់ស្ត្រីមានផ្ទៃពោះនិងកុមារ
- រៀបចំនិងអនុវត្តផែនការសកម្មភាពដើម្បីគាំពារដល់គ្រួសារគោលដៅ លើផ្នែកសេដ្ឋកិច្ច ដូចជាបង្កើតមុខរបរ ជំរុញសមាជិកគ្រួសារមានជំនាញវិជ្ជាជីវៈ គាំទ្ររបរដែលមានស្រាប់ អភិវឌ្ឍសមត្ថភាពសមាជិកគ្រួសារ បង្កើតឥណទានខ្នាតតូច
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋនិងឯកជន ដើម្បីគាំពារតម្រូវការនៃគ្រួសារក្រីក្រ គ្រួសារជនរងគ្រោះ គ្រួសារជនងាយរងគ្រោះ
- សហការជាមួយក្រសួង ស្ថាប័ន ដើម្បីលើកទឹកចិត្តក្រុមហ៊ុន សហគ្រាស បុគ្គលក្នុងការសាងសង់លំនៅឋានសង្គមកិច្ច លំនៅឋានសម្រាប់គ្រួសារក្រីក្រ គ្រួសារជីវភាពមធ្យម
- ផ្តល់សេវាប្រឹក្សាយោបល់ ការដោះស្រាយវិបត្តិដល់គ្រួសារដែលមានបញ្ហា
- សិក្សាអំពីផលប៉ះពាល់និងដំណោះស្រាយជូនគ្រួសារជនរងគ្រោះ ជនងាយរងគ្រោះ ដើម្បីទប់ស្កាត់បញ្ហាប្រឈមសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

**មាត្រា២១ .-**

នាយកដ្ឋានគាំពារជនរងគ្រោះមានភារកិច្ចដូចតទៅ៖

- កសាងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកិច្ចគាំពារជនរងគ្រោះគ្រប់ប្រភេទ
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងជនរងគ្រោះ
- ផ្តល់ជំនួយបឋមដល់ជនរងគ្រោះ
- ចងក្រងនិងគ្រប់គ្រងទិន្នន័យជនរងគ្រោះតាមករណី
- ផ្តល់ការប្រឹក្សា ពិគ្រោះយោបល់ផ្នែកច្បាប់ ផ្នែកផ្លូវចិត្ត និងជួយមធ្យោបាយនានាដល់ជនរងគ្រោះដើម្បីដោះស្រាយបញ្ហាចំពោះមុខនិងផលវិបាកនៅគ្រាបន្ទាប់
- សហការជាមួយក្រសួង ស្ថាប័ន ដើម្បីគាំពារដល់ជនរងគ្រោះលើជំនួយបន្ទាន់ រួមមាន ផ្នែកសុខភាព ផ្នែកច្បាប់ អាហារ ទីជម្រក និងជំនួយនាគ្រាបន្ទាប់
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ និងជួបគ្រោះមហន្តរាយផ្សេងៗនៅតាមសហគមន៍
- ផ្តល់សេវាថែទាំ គាំពារ ដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ ជំងឺប្រចាំកាយធ្ងន់ធ្ងរ រ៉ាំរ៉ៃ និងជំងឺកាចសាហាវផ្សេងៗ
- គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទឬទម្រង់ផ្សេងៗទៀតនៃការរំលោភបំពានតាមបែបទាសភាពសម័យទំនើប
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សរំលោភផ្លូវភេទនិងទម្រង់ផ្សេងៗទៀត

- អនុវត្តកម្មវិធីមាតុភូមិនិវត្តន៍ជនរងគ្រោះ ជនងាយរងគ្រោះ និងទម្រង់ផ្សេងៗទៀតដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទ
- អនុវត្តការកំណត់អត្តសញ្ញាណអន្តរាគមន៍វិបត្តិ ការបញ្ជូន ការទទួល ការរៀបចំផែនការករណី ការប៉ាន់ប្រមាណ ការស្តារ ការធ្វើសមាហរណកម្ម ការតាមដាន ការបិទករណី និងការឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភផ្លូវភេទ និងទម្រង់ផ្សេងៗទៀត
- គ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទគ្រប់ទម្រង់នៃការរំលោភបំពាន
- គាំពារជនរងគ្រោះនិងសាក្សីក្នុងរឿងក្តីនៅតុលាការ
- រៀបចំមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ
- សម្របសម្រួលមណ្ឌលឬមជ្ឈមណ្ឌលថែទាំជនមានវិបល្លាសស្មារតីថ្នាក់ជាតិ និងថ្នាក់តំបន់
- សម្របសម្រួលមជ្ឈមណ្ឌលសំចតសម្រាប់ផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្សរំលោភផ្លូវភេទនិងទម្រង់ផ្សេងៗទៀតដែលបានធ្វើមាតុភូមិនិវត្តន៍
- គ្រប់គ្រង និងស្រង់ស្ថិតិជនអនាថា ជនមានវិបល្លាសស្មារតីតាមទីសាធារណៈ តាមសហគមន៍ និងគ្រួសារ
- រៀបចំយន្តការបង្ការ ទប់ស្កាត់ អន្តរាគមន៍ និងឆ្លើយតបបញ្ហាជនអនាថា និងជនមានវិបល្លាសស្មារតី
- បង្កើតនិយាមគំរូដើម្បីថែទាំជនមានវិបល្លាសស្មារតីនៅសហគមន៍និងមណ្ឌលថែទាំ
- បង្កើតយន្តការកំណត់ពីការបញ្ជូន បង្វែរជនអនាថា ជនមានវិបល្លាសស្មារតីពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅសហគមន៍
- រៀបចំយន្តការវាយតម្លៃអំពីកម្រិតវិបល្លាសស្មារតី ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំយន្តការថែទាំ ព្យាបាលជនមានវិបល្លាសស្មារតី ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៧
## អគ្គនាយកដ្ឋានស្តារសម្បទា

**មាត្រា២២.-**

អគ្គនាយកដ្ឋានស្តារសម្បទា មានតួនាទីនិងភារកិច្ចផ្តល់សេវាស្តារទាំងអស់ រួមមាននីតិសម្បទា កាយសម្បទា និងបញ្ញាស្មារតី ក្នុងគោលបំណងឱ្យបុគ្គលនោះវិលត្រឡប់ទៅរកស្ថានភាពប្រក្រតី ទាំងសុខភាពបញ្ញាស្មារតី កាយសម្បទា នីតិសម្បទាដូចជនទូទៅ។

អគ្គនាយកដ្ឋានស្តារសម្បទាមាននាយកដ្ឋានចំនួន៤(បួន)ដែលមានភារកិច្ចដូចមានចែងក្នុងជំពូកនេះ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រី។

**មាត្រា២៣.-**

នាយកដ្ឋានស្តារនីតិសម្បទាអនីតិជនមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារអនីតិជន

- អនុវត្តលិខិតបទដ្ឋានគតិយុត្ត អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងអនីតិជនល្មើសច្បាប់
- រៀបចំលិខិតបទដ្ឋានគតិយុត្ត គំរូបច្ចេកទេសស្តារដល់មណ្ឌលយុវនីតិសម្បទានិងសមាហរណកម្ម
- ណែនាំលើការងារការពារមណ្ឌលយុវនីតិសម្បទា ការពារអនីតិជនល្មើសច្បាប់
- សហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ការព្យាបាល អប់រំបង្ការជំងឺ ការលើកលែងទោស ការស្តារនីតិសម្បទា កាយសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់នៅមណ្ឌលយុវនីតិសម្បទា
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល បង្កើតកម្មវិធីបង្វែរ ស្តារនីតិសម្បទា និងសមាហរណកម្មអនីតិជនល្មើសច្បាប់
- បង្កើតនិងរៀបចំយន្តការការងារស្តារនីតិសម្បទានិងសមាហរណកម្មអនីតិជនទំនាស់នឹងច្បាប់
- រៀបចំផែនការ កម្មវិធីអប់រំកែប្រែ ឥរិយាបថ កិរិយាមាយាទ និងស្តារនីតិសម្បទាដល់អនីតិជនល្មើសច្បាប់ដែលជាប់ឃុំនៅមណ្ឌលយុវនីតិសម្បទា
- បង្កើតយន្តការវាយតម្លៃលទ្ធផលអប់រំ ស្តារនីតិសម្បទា និងលទ្ធផលបណ្តុះបណ្តាលវិជ្ជាជីវៈ បូកសរុបវាយតម្លៃ លើកសំណើសុំបន្ធូរបន្ថយទោសនិងលើកលែងទោសអនីតិជនទំនាស់នឹងច្បាប់
- បង្កើតផែនការដើម្បីត្រៀមរៀបចំធ្វើសមាហរណកម្មអនីតិជនជាប់ឃុំក្នុងមណ្ឌលទៅក្នុងសហគមន៍
- សហការជាមួយគ្រឹះស្ថានសិក្សា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុន ដើម្បីទទួលយកអនីតិជនក្រោយពេលធ្វើសមាហរណកម្ម
- ពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធីស្តារនិងផែនការសមាហរណកម្ម
- បង្កើតមុខរបរដល់អ្នកដែលបានស្តារនីតិសម្បទា
- រៀបចំនីតិវិធី ទម្រង់ បែបបទ និងយន្តការស្តីពីការបង្វែរអនីតិជន តាមការកំណត់នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- រៀបចំបណ្តុះបណ្តាលភ្នាក់ងារសង្គមកិច្ចក្នុងគោលដៅបម្រើឱ្យការងារបង្វែរអនីតិជន
- សហការជាមួយអង្គភាពនគរបាលដើម្បីជំរុញឱ្យមានការអនុវត្តការចេញសេចក្តីព្រមានសម្រាប់បទល្មើសលហុដែលប្រព្រឹត្តដោយអនីតិជន និងមានការចូលរួមតាមដានទៀងទាត់ពីមន្ត្រីពាក់ព័ន្ធ
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបទល្មើសប្រព្រឹត្តដោយអនីតិជនក្នុងកម្រិតស្រាលនិងមធ្យមតាមបទប្បញ្ញត្តិកំណត់ជាធរមាន ដោយផ្តោតជាសំខាន់លើវិធានការបង្វែរ
- សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនិងស្ថាប័នតុលាការ ដើម្បីធានាថាវិធានការបង្វែរត្រូវបានអនុវត្តស្របតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងគោលការណ៍ណែនាំស្តីពីការបង្វែរ
- សហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរកជំនួយផ្នែកច្បាប់ជួយអនីតិជនល្មើសច្បាប់នៅគ្រប់ដំណាក់កាលនៃនីតិវិធី
- ចាត់ចែងតាមនីតិវិធីចំពោះអនីតិជនដែលបរាជ័យលើកម្មវិធីបង្វែរ
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន ដើម្បីគាំទ្រដល់កម្មវិធីបង្វែរ។

**មាត្រា២៤.-**

នាយកដ្ឋានគាំពារអ្នកញៀនគ្រឿងញៀនមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារអ្នកញៀនគ្រឿងញៀន
- អនុវត្តលិខិតបទដ្ឋានគតិយុត្ត អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងកិច្ចគាំពារអ្នកញៀនគ្រឿងញៀន
- គ្រប់គ្រងសេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌល
- បង្កើតនិងរៀបចំយន្តការសមាហរណកម្មអ្នកញៀនគ្រឿងញៀនទៅក្រុមគ្រួសារនិងសហគមន៍
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកញៀនគ្រឿងញៀននៅក្នុងមជ្ឈមណ្ឌលនិងសហគមន៍ និងបង្កើតមុខរបរ
- អប់រំ ផ្សព្វផ្សាយ ដល់មហាជនពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន
- បង្កើតគំរូនៃកម្មវិធីស្តារកាយសម្បទានិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
- រៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ លក្ខខណ្ឌ សម្រាប់បង្កើតមណ្ឌល មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក្នុងក្របខណ្ឌឯកជននិងរដ្ឋ
- ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបង្កើតនិងដឹកនាំ គ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកម្រិតមូលដ្ឋាននៅរាជធានី ខេត្ត
- តាមដាន សម្របសម្រួលផ្នែកបច្ចេកទេសនិងការគ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននិងកម្មវិធីស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ ឯកជន និងតាមសហគមន៍
- សហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌល មណ្ឌល និងសហគមន៍។

**មាត្រា២៥.-**

នាយកដ្ឋានសុខុមាលភាពជនពិការមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសពាក់ព័ន្ធនឹងសុខុមាលភាពជនពិការ
- រៀបចំផែនការសកម្មភាពនិងថវិកាសម្រាប់ការងារសុខុមាលភាពជនពិការ
- អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងពិការភាព
- អនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងពិការភាព
- ចូលរួមកំណត់បទដ្ឋានស្តង់ដាបច្ចេកទេសពាក់ព័ន្ធនឹងវិស័យពិការភាព
- ចូលរួមអនុវត្តការងារស្តារលទ្ធភាពពលកម្ម គាំពារសុខុមាលភាពជនពិការ បង្កលក្ខណៈងាយស្រួល ដល់ជីវភាពរស់នៅរបស់ជនពិការគ្រប់ប្រភេទ

- អភិវឌ្ឍន៍ធនធានជនពិការ អប់រំផ្សព្វផ្សាយ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កំណត់អត្តសញ្ញាណពិការភាព ធ្វើស្ថិតិជនពិការ សិក្សាស្រាវជ្រាវនិងធ្វើអធិការកិច្ចពិការភាពតាមបណ្តាក្រសួង ស្ថាប័នរដ្ឋនិងវិស័យឯកជន
- ចូលរួមគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាតាមភូមិភាគ និងរាជធានី ខេត្ត
- អភិវឌ្ឍន៍សេវាពិការភាព ការស្តារលទ្ធភាពពលកម្ម កាយសម្បទា កម្មវិធីអភិវឌ្ឍន៍សហគមន៍ប្រកបដោយបរិយាបន្ន និងគាំពារសុខុមាលភាពជនពិការ
- អភិវឌ្ឍន៍ធនធានពិការភាព ការអប់រំផ្សព្វផ្សាយ ការបណ្តុះបណ្តាលការងារ មុខរបរ ការអភិវឌ្ឍជំនាញនិងកម្មវិធីសិក្សាសម្រាប់ជនពិការ
- ដឹកនាំ ចាត់ចែង និងអភិវឌ្ឍកម្មវិធីកំណត់អត្តសញ្ញាណពិការភាព និងគ្រប់គ្រងទិន្នន័យជនពិការ
- រៀបចំធ្វើអង្កេតឬការសិក្សាស្រាវជ្រាវ និងការចងក្រងឯកសារពិសោធន៍នានា ដើម្បីអភិវឌ្ឍការងារពិការភាព
- ធ្វើអធិការកិច្ចការងារពិការភាពតាមបណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជន ក្នុងការអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយដឹកជញ្ជូន មធ្យោបាយទំនាក់ទំនងឌីជីថលនិងបច្ចេកវិទ្យាព័ត៌មាននិងជំនួយបុគ្គល
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យសិល្បៈនិងកីឡាជនពិការ
- កៀរគរធនធានពីដៃគូអភិវឌ្ឍវិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ដើម្បីអភិវឌ្ឍការងារសុខុមាលភាពជនពិការ
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីនានាពាក់ព័ន្ធនឹងការងារសុខុមាលភាពជនពិការ។

**មាត្រា២៦ .-**

មូលនិធិសង្គមកិច្ចមានភារកិច្ចដូចតទៅ៖

- កៀរគរនិងគ្រប់គ្រងធនធាន ព្រមទាំងសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍ ក្រុមហ៊ុនសហគ្រាស ស្ថាប័ននានា និងសប្បុរសជនទូទៅ ដើម្បីទ្រទ្រង់សកម្មភាពការងារសង្គមកិច្ច
- លើកកម្ពស់សមត្ថភាពបុគ្គលិកសង្គមកិច្ចនិងអ្នកស្ម័គ្រចិត្តពាក់ព័ន្ធ ដើម្បីធានាគុណភាពនិងធនធានមនុស្សក្នុងការផ្តល់សេវាសង្គមកិច្ច
- បង្កើតព្រឹត្តិការណ៍សប្បុរសធម៌ ដើម្បីលើកកម្ពស់សកម្មភាពការងារសង្គមកិច្ច
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ក្នុងគោលបំណងលើកទឹកចិត្តនិងជំរុញការគាំទ្រផ្នែកសម្ភារៈនិងស្មារតីឬសកម្មភាពដើម្បីបុព្វហេតុសង្គមកិច្ច
- ផលិតកម្មវិធី ទស្សនីយភាព តាមវិទ្យុ ទូរទស្សន៍ និងផ្ទាំងរូបភាព ដើម្បីអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ការងារសង្គមកិច្ច

- រៀបចំលិខិតសរសើរ បណ្ណសរសើរ លិខិតថ្លែងអំណរគុណ គ្រឿងឥស្សរិយយស ពានរង្វាន់ និងផ្តល់រង្វាន់ ផ្តល់ឋានៈសម្រាប់នីតិបុគ្គល រូបវន្តបុគ្គលដែលមានស្នាដៃក្នុងបុព្វហេតុសង្គមកិច្ច ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជី និងរបាយការណ៍ដៃគូអភិវឌ្ឍ ក្រុមហ៊ុន សហគ្រាស ស្ថាប័ននានា និងសប្បុរសជនទូទៅដែលបានចូលរួមសកម្មភាពការងារសង្គមកិច្ច។

## ជំពូកទី៨
## អគ្គាធិការដ្ឋាន

**មាត្រា២៧.-**

អគ្គាធិការដ្ឋានមានតួនាទីជាសេនាធិការឱ្យក្រសួងលើការងារ៖

- ធ្វើអធិការកិច្ចជាប្រចាំលើគ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ពិនិត្យ សម្របសម្រួល និងដោះស្រាយវិវាទរដ្ឋបាលដែលពាក់ព័ន្ធដល់សមត្ថកិច្ចនិងសកម្មភាពរបស់មន្ត្រីនិងភ្នាក់ងាររបស់ក្រសួង
- ពិនិត្យការអនុវត្តគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តនានាតាមអង្គភាពក្រោមឱវាទក្រសួង
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ច និងលើកវិធានការកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា២៨.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅសវនកម្មផ្ទៃក្នុងតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈនិងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## វិទ្យាស្ថានជាតិសង្គមកិច្ច មណ្ឌលយុវនីតិសម្បទា
## និងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

**មាត្រា២៩.-**

វិទ្យាស្ថានជាតិសង្គមកិច្ច មានបេសកកម្មបណ្តុះបណ្តាលនិងស្រាវជ្រាវលើផ្នែកសង្គមកិច្ច ដោយភ្ជាប់ទៅនឹងតម្រូវការរបស់ប្រទេសជាតិនិងសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានជាតិសង្គមកិច្ចត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៣០.-**

មណ្ឌលយុវនីតិសម្បទា មានបេសកកម្មជានាការពារសិទ្ធិ សុវត្ថិភាព និងលើកស្ទួយសុខុមាលភាពរាងកាយនិងស្មារតីរបស់អនីតិជនជាប់ឃុំនៅមណ្ឌលយុវនីតិសម្បទា ស្របតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

**មាត្រា៣១.-**

មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន មានបេសកកម្មបន្សាប ព្យាបាល អប់រំ ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀនចូលទៅក្នុងសហគមន៍និងក្រុមគ្រួសារវិញ ដើម្បីរួមចំណែកក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី១១
## គ្រឹះស្ថានសាធារណៈរដ្ឋបាល

**មាត្រា៣២.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាន៖

- មូលនិធិជនពិការ
- មូលនិធិជាតិជំនួយសង្គម។

គ្រឹះស្ថានសាធារណៈរដ្ឋបាលដទៃទៀតអាចត្រូវបង្កើតឡើងក្នុងករណីចាំបាច់ ដោយយោងទៅតាមតម្រូវការនិងការអភិវឌ្ឍវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅព្រះរាជាណាចក្រកម្ពុជា។

គ្រឹះស្ថានសាធារណៈរដ្ឋបាលនានា ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី១២
## មណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈមណ្ឌលតំបន់

**មាត្រា៣៣.-**

មណ្ឌល មជ្ឈមណ្ឌលជាតិ និងមជ្ឈមណ្ឌលតំបន់ដែលចំណុះក្រសួង មានតួនាទីនិងភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារស្របតាមលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី១៣
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា៣៤.-**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត បំពេញមុខងារជាតំណាងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការសម្របសម្រួលនិងគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១៤

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៣៥.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្ដាក្រសួង។

## ជំពូកទី១៥

## បទប្បញ្ញត្តិដោយឡែក

**មាត្រា៣៦.-**

មន្ត្រីរាជការនិងភ្នាក់ងារសង្គមកិច្ចដែលត្រូវបានចាត់តាំងឱ្យបំពេញការងារប្រតិបត្តិផ្ទាល់ជាមួយអ្នកទទួលសេវាសង្គមកិច្ច ត្រូវមានឯកសណ្ឋាននិងរូបសញ្ញាសម្គាល់។

ឯកសណ្ឋាននិងរូបសញ្ញាសម្គាល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

ភ្នាក់ងារសង្គមកិច្ចបញ្ញត្តិក្នុងមាត្រានេះ សំដៅដល់មន្ត្រីរបស់ក្រសួង ស្ថាប័ន អង្គភាព មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្ដុះបណ្ដាលជំនាញពាក់ព័ន្ធនឹងសង្គមកិច្ច ហើយត្រូវបានទទួលការតែងតាំងឬទទួលស្គាល់ពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## ជំពូកទី១៦

## អន្តរប្បញ្ញត្តិ

**មាត្រា៣៧.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពនានាចំណុះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

## ជំពូកទី១៧

## អវសានប្បញ្ញត្តិ

**មាត្រា៣៨.-**

អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

រចនាសម្ព័ន្ធអង្គភាពនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក
ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២២



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៦១.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប របស់ក្រសួងពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោម៖

១-លោក **ជា ធីរៈ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២-លោក **ខុង ម៉ុនរ័ត្ន** ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៦៤ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ថ្នាក់វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

១-វរសេនីយ៍ទោ **ឃឿម ធានី** អត្តលេខ ២០៦៣២៧ នាយការិយាល័យផែនការហ្វឹកហ្វឺន មហាវិទ្យាល័យព័ត៌មានវិទ្យា និងភស្តុភារហិរញ្ញវត្ថុយោធា សាកលវិទ្យាល័យការពារជាតិ

២-វរសេនីយ៍ទោ **មាន ជាចលី** អត្តលេខ ១១០៤៣៨ នាយការិយាល័យគ្រប់គ្រងបណ្ណាល័យ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ឯកសារ និងបណ្ណាល័យ សាកលវិទ្យាល័យការពារជាតិ

៣-វរសេនីយ៍ទោ **យាត សុស្តី** អត្តលេខ ០៥៨១៧៨ យោធាចារ្យសេដ្ឋកិច្ចយោធា មជ្ឈមណ្ឌលកិច្ចការ សាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

៤-វរសេនីយ៍ទោ **ណោន វណ្ណៈ** អត្តលេខ ១៦៣៩២៧ នាយការិយាល័យភស្តុភារ
សាកលវិទ្យាល័យការពារជាតិ

៥-វរសេនីយ៍ទោ **ប៉ុន សារឿន** អត្តលេខ ០៣៣៨២៣ នាយការិយាល័យគ្រប់គ្រងនិស្សិត
មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រោយបរិញ្ញាបត្រ សាកលវិទ្យាល័យការពារជាតិ

៦-វរសេនីយ៍ទោ **វាន់ រតនៈ** អត្តលេខ ១៥១៥៣៧ នាយការិយាល័យកិច្ចការស្រាវជ្រាវ
មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រោយបរិញ្ញាបត្រ សាកលវិទ្យាល័យការពារជាតិ

៧-វរសេនីយ៍ទោ **អ៊ុយ វិចិត្រ** អត្តលេខ ២២៤០៤៣ នាយមុខវិជ្ជាគ្រូពាណិជ្ជកម្ម
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

៨-វរសេនីយ៍ទោ **គង់ សាបាន** អត្តលេខ ០៨២៨៧៦ យោធាចារ្យយុទ្ធវិធី
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

៩-វរសេនីយ៍ទោ **កើត តាត** អត្តលេខ ១៦៣៣៦៣ យោធាចារ្យយុទ្ធវិធី
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១០-វរសេនីយ៍ទោ **រ័ត្ន មូរ៉ា** អត្តលេខ ០៥៨៤០២ នាយមុខវិជ្ជាគ្រូបច្ចេកទេសយោធា
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១១-វរសេនីយ៍ទោ **សួន ម៉ានិត្យ** អត្តលេខ ០៦៦៧៥០ នាយមុខវិជ្ជាគ្រូស្រាវជ្រាវ វិទ្យាសាស្ត្រយោធា
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១២-វរសេនីយ៍ទោ **ឈីត្ត រាលស៊ូម៉ារ៉ា** អត្តលេខ ០១១៤៧៥ នាយមុខវិជ្ជាគ្រូទំនាក់ទំនងអន្តរជាតិយោធា
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៣-វរសេនីយ៍ទោ **ខាន វណ្ណៈ** អត្តលេខ ០៨២៩៨៧ នាយមុខវិជ្ជាគ្រូរូបវិទ្យា
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៤-វរសេនីយ៍ទោ **ប្រាក់ ប៊ុនសុខ** អត្តលេខ ០៦៨៩៥៩ នាយមុខវិជ្ជាគ្រូកងទ័ពអាកាស
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៥-វរសេនីយ៍ទោ **សាន សុភ័ក្ត្រ** អត្តលេខ ២១១២២៦ នាយមុខវិជ្ជាគ្រូវិទ្យាសាស្ត្រនយោបាយ
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៦-វរសេនីយ៍ទោ **កេត រតនា** អត្តលេខ ០៥៨៣៧១ នាយមុខវិជ្ជាគ្រូគរុកោសល្យយោធា
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៧-វរសេនីយ៍ទោ **ចាន់ ស៊ីផាត** អត្តលេខ ០៥៧៩២៥ នាយការិយាល័យអប់រំចិត្តសាស្ត្រ
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

១៨-វរសេនីយ៍ទោ **អ៊ុក តិរុណា** អត្តលេខ ០៣២៤២៥ នាយការិយាល័យផែនការហ្វឹកហ្វឺន
មជ្ឈមណ្ឌលបណ្តុះបណ្តាលក្រោយបរិញ្ញាបត្រ សាកលវិទ្យាល័យការពារជាតិ

១៩-វរសេនីយ៍ទោ **គឹម ដារ៉ា** អត្តលេខ ០០៨៦៨៣ នាយមុខវិជ្ជាគ្រូកាំភ្លើងធំ
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

២០-វរសេនីយ៍ទោ **វណ្ណា ម៉ារីណា** អត្តលេខ ១៩០៨៦៣ ជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ឯក
**ចាន់ ពន្លឺក** សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

២១-វរសេនីយ៍ទោ **ស៊ឹម សុភាព** អត្តលេខ ០២៨៨៩០ យោធាចារ្យ យោធាតំបន់
មជ្ឈមណ្ឌលកិច្ចការសាស្ត្រាចារ្យ យោធាចារ្យ សាកលវិទ្យាល័យការពារជាតិ

២២-វរសេនីយ៍ទោ **ឃិន រដ្ឋា** អត្តលេខ ២២៦០៤៧ នាយការិយាល័យគ្រប់គ្រងនិស្សិត មហាវិទ្យាល័យការពារជាតិ សាកលវិទ្យាល័យការពារជាតិ

២៣-វរសេនីយ៍ទោ **ឃិន ច័ន្ទសីមា** អត្តលេខ ២៣០២២៥ នាយការិយាល័យផែនការហ្វឹកហ្វឺន មហាវិទ្យាល័យការពារជាតិ សាកលវិទ្យាល័យការពារជាតិ

២៤-វរសេនីយ៍ទោ **សុខន អណិកា** អត្តលេខ ១៦៣៣៦៦ នាយការិយាល័យផែនការហ្វឹកហ្វឺន មហាវិទ្យាល័យ វិទ្យាសាស្ត្រ សង្គម និងភាសា សាកលវិទ្យាល័យការពារជាតិ

២៥-វរសេនីយ៍ទោ **ទ៉ែត ទិវ័យតារា** អត្តលេខ ០៥០៤៧០ នាយការិយាល័យពិសោធន៍ភាសា និងបណ្ណាល័យមហាវិទ្យាល័យ វិទ្យាសាស្ត្រ សង្គម និងភាសា សាកលវិទ្យាល័យការពារជាតិ

២៦-វរសេនីយ៍ទោ **ចាន់ សុខេង** អត្តលេខ ២១២៨៣៥ នាយការិយាល័យគ្រប់គ្រងនិស្សិត និងសិក្ខាកាមមហាវិទ្យាល័យ វិទ្យាសាស្ត្រ សង្គម និងភាសា សាកលវិទ្យាល័យការពារជាតិ

២៧-វរសេនីយ៍ទោ **ដាញ់ សារ៉េត** អត្តលេខ ២២៥៩៨០ នាយលេខាធិការដ្ឋាន មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និងភាសា សាកលវិទ្យាល័យការពារជាតិ

២៨-វរសេនីយ៍ទោ **ម៉េង សុគា** អត្តលេខ ០៧៣៧២២ ជំនួយការ នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

២៩-វរសេនីយ៍ទោ **ថុង សុធារិទ្ធ** អត្តលេខ ១៦៦១៩២ ជំនួយការ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៣០-វរសេនីយ៍ទោ **អ៊ិត សុជាតា** អត្តលេខ ២៣០១១២ ជំនួយការ ឯកឧត្តម នាយក នាយកដ្ឋានបុគ្គលិក

៣១-វរសេនីយ៍ទោ **ហួយ សំអូន** អត្តលេខ ០៥៨៥៨៣ នាយការិយាល័យវេទិកាតំបន់អាស៊ាន នាយកដ្ឋានកិច្ចការអាស៊ាន អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣២-វរសេនីយ៍ទោ **ស៊ីម សន** អត្តលេខ ១៨៧៨៥៦ នាយកស្នការ នាយកដ្ឋានកិច្ចការអាស៊ាន អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៣-វរសេនីយ៍ទោ **ហ៊ាន ភិត្យា** អត្តលេខ ០៣៧៦៣៨ នាយការិយាល័យប្រតិកម្មរហ័ស អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៤-វរសេនីយ៍ទោ **សរ អន្ធារ៉ា** អត្តលេខ ២១៦៣៧៣ នាយការិយាល័យបច្ចេកទេស និងយានយន្ត អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៥-វរសេនីយ៍ទោ **ម៉ិល គុណាពិសិដ្ឋ** អត្តលេខ ០២៤៦៧២ នាយការិយាល័យផែនការ នាយកដ្ឋាននយោបាយផែនការ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៦-វរសេនីយ៍ទោ **ឃី បូរិទ្ធ** អត្តលេខ ១៦៣៧៣២ នាយការិយាល័យគ្រប់គ្រងអនុព័ន្ធយោធា អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៧-វរសេនីយ៍ទោ **ម៉ន ចំរ៉ុង** អត្តលេខ ១៦៣៧៥៩ នាយលេខាធិការដ្ឋាន វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៨-វរសេនីយ៍ទោ **ខាំ សម្បត្តិ** អត្តលេខ ១៦៤៣៣៤ នាយការិយាល័យប្រវត្តិសាស្ត្រ សិក្សាយុទ្ធ និងយុទ្ធវិធី វិទ្យាស្ថានប្រវត្តិសាស្ត្រយោធា អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៣៩-វរសេនីយ៍ទោ **មួន សុខឌី** អត្តលេខ ០២១៧៤៩ នាយការិយាល័យពិធីការ នាយកដ្ឋានទាក់ទងអន្តរជាតិ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៤០-វរសេនីយ៍ទោ **ណៃ សុគ័ណ្ណា** អត្តលេខ ០២៤៦៧០ នាយកស្នការ នាយកដ្ឋាននយោបាយផែនការ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

៤១-វរសេនីយ៍ទោ **សួន ទិទ្ធ** អត្តលេខ ២១៦៣៨៦ នាយករង នាយកដ្ឋាននយោបាយផែនការ អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

| | | | | |
|---|---|---|---|---|
| ៤២-វរសេនីយ៍ទោ | **ចណ្ណា** | **សុគន្ធ** | អត្តលេខ ០២៥៣៤០ | ជំនួយការ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ន័យ ផុល** ប្រធាន ស្ថាប័នតុលាការយោធា |
| ៤៣-វរសេនីយ៍ទោ | **នុំ** | **ជិត** | អត្តលេខ ០២៥៣៦៨ | នាយការិយាល័យក្រឡាបញ្ជី ស្ថាប័នតុលាការយោធា |
| ៤៤-វរសេនីយ៍ទោ | **គុំ** | **សុបិន** | អត្តលេខ ០៣១៥៩៩ | នាយសុខាភិបាល ស្ថាប័នតុលាការយោធា |
| ៤៥-វរសេនីយ៍ទោ | **សេខ** | **ស៊ាន** | អត្តលេខ ២៣១៦១៣ | ចៅក្រម ស្ថាប័នតុលាការយោធា |
| ៤៦-វរសេនីយ៍ទោ | **គង់** | **សារឿន** | អត្តលេខ ០២៥៣៧៣ | ចៅក្រម ស្ថាប័នតុលាការយោធា |
| ៤៧-វរសេនីយ៍ទោ | **ឃីម** | **រ៉ាម៉ូ** | អត្តលេខ ០៤៨០១៧ | នាយលេខាធិការដ្ឋាន ស្ថាប័នតុលាការយោធា |
| ៤៨-វរសេនីយ៍ទោ | **ពុធ** | **សារីម** | អត្តលេខ ០២៥៣៧៨ | នាយការិយាល័យចៅក្រមស៊ើបសួរ ស្ថាប័នតុលាការយោធា |
| ៤៩-វរសេនីយ៍ទោ | **ទូច** | **ផាន់ណា** | អត្តលេខ ២៣០២៣៣ | ជំនួយការ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ២ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

**លេខ :** ៤៦៣..អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់លោក **ពិន សុភ័ណ្ឌា** ពីឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ នៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៅក្រសួងសុខាភិបាល។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ២៦៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងថ្នាក់តាមកម្រិតសញ្ញាបត្រ ដល់លោក **ខោ ទីរីយ៉ា** ពីឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៅក្រសួងសុខាភិបាល។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ២ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

៩
៤

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៦៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែក ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

## សម្រេច

**មាត្រា ១ .-** តម្លើងថ្នាក់ប្រចាំឆ្នាំ ២០២២ ដល់មន្ត្រីរាជការចំនួន ៥២ រូប ក្នុងឋានន្តរស័ក្តិសវនករដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក **សិទ្ធី បញ្ញាឫទ្ធិ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២-លោកស្រី **ហេង បូធីតា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣-លោក **ម៉ែន ដាណា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤-លោកស្រី **អៀន សារ៉ឹម** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៥-លោក **សេខ ធីរិទ្ធ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៦-លោក **ខត្យ វិចិត្រ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៧-លោក **អៀច សុវណ្ណចន្ទត្រា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |

| | | |
|---|---|---|
| ៨-លោក **ខន គុនហ៊ាង** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៩-លោក **ម៊ុន វណ្ណារិទ្ធ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១០-លោក **មាន ច័ន្ទណារិទ្ធ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១១-លោក **ឡោក ជំនាញ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១២-លោក **ខេង វិសាល** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៣-លោក **ហាស់ វិចិត្រ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៤-លោក **ណាយ វណ្ណាវិសិទ្ធិ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៥-លោកស្រី **ម៉ុល សុផល** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៦-លោក **ម៉ែន ច័ន្ទរិទ្ធី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៧-លោក **ជួង សុធារតន៍** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៨-លោកស្រី **ឃុន ពិដោរ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៩-លោក **ឈួក សុខសាន្ត** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២០-លោក **ណុប ស៊ីណា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២១-លោក **ថាម សុខគង់** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២២-លោកស្រី **អ៊ុំ រស្មី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៣-លោកស្រី **ម៊ុន ស៊ីណែត** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៤-លោកស្រី **ភូង សុតា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៥-លោក **ឌឹម បូរ៉ា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៦-លោកស្រី **ថេត ថាវី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៧-លោក **ប៉ា សុផារី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៨-លោកជំទាវ **ម៉ម រមនា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២៩-លោក **ហា វ៉ាន់ដា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣០-លោក **អ៊ុង សំបូរ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣១-លោក **យ៉េម តូរិទ្ធ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣២-លោក **លឹម ឡុងឌី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៣-លោក **លី សុខហួរ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៤-លោក **វ៉ន វីរៈ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៥-លោក **ហែម វិមល** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៦-លោក **ប្រាជ្ញ ឈៀងលី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៧-លោកស្រី **ថន ម៉ាដានី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៨-លោក **អ៊ុង សំអាន** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣៩-លោកស្រី **វ៉ាន់ ធានី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |

| | | |
|---|---|---|
| ៤០-លោក **សុណា សាន់ដេ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤១-លោក **សេង កុសល** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤២-លោក **សុខ ធីរៈ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៣-លោកស្រី **យ៉េត ម៉ូលិះ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៤-លោក **កុយ មករា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៥-លោក **ហ៊ឹម សុគន្ធា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៦-លោកស្រី **ហ៊ាង សុជាតា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៧-លោក **អ៊ុក ធីរៈ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤៨-លោក **សោម ប៉ាទ្រី** | ពីសវនករដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៤៩-លោកស្រី **ឌី ស្រីអូន** | ពីសវនករដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៥០-លោក **ហ៊ល ផល្លីន** | ពីសវនករដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៥១-លោក **សុក សុគន្ធិ** | ពីសវនករដើមខ្សែ ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៥២-លោក **រិទ្ធី សុវណ្ណារា** | ពីសវនករដើមខ្សែ ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែចេត្រ ឆ្នាំខាលចត្វាស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៦៦ អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

តម្លើងឋានន្តរស័ក្តិ **លោក យឹម សុវណ្ណឡង់ឌី** អត្តលេខ ២៣១៤ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ ២ មកជា ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ២.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ចន្ទ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១ ៖** ត្រូវបានដកហូតឋានន្តរស័ក្តិថ្នាក់ វរសេនីយ៍ឯក ពីវរសេនីយ៍ឯក **ង៉ែត រតនៈ** អត្តលេខ ៥៦៤៤២ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៣ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

តម្លើងឋានន្តរស័ក្តិវរអគ្គានុរក្សដល់មន្ត្រីពន្ធនាគារ **ចំនួន ០៥ រូប** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ មានរាយនាមដូចខាងក្រោម៖

១- **លោក មៀច សុវណ្ណា** អត្តលេខ ១៤២៨ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ **២** មកជា ថ្នាក់លេខ ១
២- **លោក សៀក សុវណ្ណារ៉ា** អត្តលេខ ១៤៦៧ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ **២** មកជា ថ្នាក់លេខ ១
៣- **លោក អ៊ុយ សទ្ធា** អត្តលេខ ០៣៦២ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ **២** មកជា ថ្នាក់លេខ ១
៤- **លោក ជា សុភ័ក្រ** អត្តលេខ ៣៣៣៧ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ **២** មកជា ថ្នាក់លេខ ១
៥- **លោក ជុំ សុវណ្ណាលី** អត្តលេខ ០៨២៣ ពីឋានន្តរស័ក្តិវរអគ្គានុរក្ស ថ្នាក់លេខ **២** មកជា ថ្នាក់លេខ ១

**មាត្រា ២.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

និយ័តកម្មតម្លើងក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ដល់មន្ត្រីរាជការ ចំនួន **១៣ រូប** មកក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ មានរាយនាមដូចខាងក្រោម ៖

១- លោក **ហួន សំបុល** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៥ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៣
២- លោក **ហុង ជំនោរ** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៥ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៣
៣- លោក **សេង ចំរើន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៥ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៣

៤- លោក **ផល រ៉ា** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៥ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៣

៥- លោកស្រី **ប៉ុក សម្ផស្ស** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាក្រមការដើមខ្សែ ថ្នាក់លេខ ៤

៦- លោក **ម៉ាល់ សុខុន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៦ មកជាក្រមការ ថ្នាក់លេខ ២

៧- លោកស្រី **សេង អញ្ញា** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ មកជាក្រមការ ថ្នាក់លេខ ២

៨- លោកស្រី **សុផាត ស្រីម៉ុន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៧ មកជាក្រមការ ថ្នាក់លេខ ២

៩- លោក **មួន ចំរើន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាក្រមការ ថ្នាក់លេខ ២

១០- លោក **ទៅ ស៊ុំ** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាក្រមការ ថ្នាក់លេខ ២

១១- លោក **ឡុង ច័ន្ទពន្លឺ** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាក្រមការ ថ្នាក់លេខ ២

១២- លោក **យៅ គីមឆ័ង** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៨ មកជាក្រមការ ថ្នាក់លេខ ២

១៣- លោក **តាស់ ផាណារ័ត្ន** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ មកជាក្រមការ ថ្នាក់លេខ ២។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

*ថ្ងៃព្រហស្បតិ៍ ៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២២ ✓*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧០ អនក្រ.តត

# អនុក្រឹត្យ

ស្តីពី

ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បកចុះថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១** : តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន **០៦ រូប** ដូចមាននាមខាងក្រោម៖

| | | |
|---|---|---|
| ១.លោក | **គីម ចំរើន** | ប្រគល់ភារកិច្ចឱ្យបំពេញមុខងារ ជាអគ្គនាយករងការងារ |
| ២.លោក | **ម៉ុន ឧត្តី** | ប្រគល់ភារកិច្ចឱ្យបំពេញមុខងារ ជាអគ្គនាយករង រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣.លោក | **អ៊ុក ចាន់ធូ** | ជាអគ្គនាយករងការងារ |
| ៤.លោក | **ស្រ៊ុន ចន្ថុល** | ជាអគ្គនាយករងការងារ |
| ៥.លោក | **ស្វាយ វិចិត្រ** | ជាអគ្គាធិការរង |

៦.លោក **ខេម ប៊ុនឈាន** ជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ ជំនួសលោក **អ៊ុក ចាន់ធូ** ដែលត្រូវទទួលភារកិច្ចថ្មី។

**មាត្រា ២** : ប្រគល់ភារកិច្ចជូនលោក **អាំង សេងលី** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានវិវាទការងារ នៃអគ្គនាយកដ្ឋានការងារ ជំនួស លោក **ជ្រុន ថេរ៉ាវង្ស** ដែលផ្ទេរចេញ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃ ចន្ទ ៤ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧១ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យ ២៩ អនុក្រ.បក ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការប្រែក្លាយ និងដំឡើងមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ទៅជាវិទ្យាស្ថានជាតិអាកាសចរស៊ីវិល មានថ្នាក់ស្មើអគ្គនាយកដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១** : តែងតាំងមន្ត្រីរាជការចំនួន០២ រូប នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖

១. លោក **សោម ឆវី** ជានាយករងវិទ្យាស្ថានជាតិអាកាសចរស៊ីវិល

២. លោក **ផូន ចរិយា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២២ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីរំលឹកខួបលើកទី៤៥ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧ - ២០ មិថុនា ២០២២ នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច១៦ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការការបង្កើតក្រសួងការពារជាតិ
- បានឃើញសេចក្តីសម្រេចលេខ១៤០សសរ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការសម្រាប់សិក្សា និងរៀបចំសាងសង់ស្តូបអនុស្សាវរីយ៍នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា តាមរយៈនយោបាយឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានគណៈកម្មការសាងសង់វិមានឈ្នះ ឈ្នះ

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីរំលឹកខួបលើកទី៤៥ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧ - ២០ មិថុនា ២០២២ នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម អ៊ិច១៦ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចតទៅ ៖

១. សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន

| | | | |
|---|---|---|---|
| ២. នាយឧត្តមសេនីយ៍ | សៅ សុខា | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធានប្រចាំការ |
| ៣. ឧត្តមសេនីយ៍ឯក | ខៀវ ធេន | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យសម្តេចពិជ័យសេនា | សមាជិក |
| ៤. ឧត្តមសេនីយ៍ឯក | ច័ន្ទ សុកគ្រា | នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន | សមាជិក |
| ៥. ឧត្តមសេនីយ៍ឯក | ផាត វិបុលសុកគ្រ | អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស និងជានាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ | សមាជិក |

៦. តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ — សមាជិក
៧. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
៨. តំណាងក្រសួងមហាផ្ទៃ — សមាជិក
៩. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — សមាជិក
១០. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
១១. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
១២. តំណាងក្រសួងព័ត៌មាន — សមាជិក
១៣. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ — សមាជិក
១៤. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ — សមាជិក
១៥. តំណាងក្រសួងទេសចរណ៍ — សមាជិក
១៦. តំណាងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន — សមាជិក
១៧. តំណាងកងទ័ពជើងគោក — សមាជិក
១៨. តំណាងកងទ័ពជើងអាកាស — សមាជិក
១៩. តំណាងអគ្គិសនីកម្ពុជា — សមាជិក
២០. អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ — សមាជិក។

**ប្រការ២._**

គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ជាសេនាធិការឱ្យរាជរដ្ឋាភិបាល
- ដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងអនុវត្តលើការងាររៀបចំពិធីនេះ
- សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដូចជាអង្គភាពឈរជើងតាមតំបន់នីមួយៗ ទាំងខាងភាគីកម្ពុជានិងភាគីវៀតណាម
- ធានាលើការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស សន្តិសុខ និងសណ្តាប់ធ្នាប់
- ធ្វើបច្ចុប្បន្នភាពការងារ រៀបចំរបាយការណ៍សកម្មភាព និងលទ្ធផលការងារជាប្រចាំ
- រៀបចំផែនការលម្អិត និងលើកគម្រោងថវិកាសម្រាប់ចំណាយ
- ធ្វើរបាយការណ៍លទ្ធផលការងារ ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗ ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ជូនអនុប្រធានប្រចាំការដឹកនាំជំនួស ។ អង្គប្រជុំនេះអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំបាន ។

**ប្រការ៤.-**

គណៈកម្មការអន្តរក្រសួងនេះ អាចមានក្រុមការងារបច្ចេកទេស សម្រាប់ទទួលបន្ទុកការងារខ្លឹមសារ ការងារសន្តិសុខ ការងារពិធីការ ការងារជានា ការងារផ្សព្វផ្សាយព័ត៌មាន ការងារផ្សេងៗ និងការងារទំនាក់ទំនងជាមួយមន្ត្រីមូលដ្ឋាននិងភាគីវៀតណាម ដើម្បីដំណើរការរៀបចំពិធីនេះ ។ សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង ។

**ប្រការ៥.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទំនាក់ទំនងការងារ ។

គណៈកម្មការអន្តរក្រសួងនេះ មានកញ្ចប់ថវិកាសម្រាប់ដំណើរការងាររបស់ខ្លួន ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៤ កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ច ទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្មមាត្រា៧ និងមាត្រា២០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## **សម្រេច**

**ប្រការ១ .-**

បង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម | **ជាប សត្ថារតន៍** | រដ្ឋលេខាធិការប្រចាំការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៣. ឯកឧត្តម | **អៀង ស៊ិនលី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម | **ខូច មករា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៥. ឯកឧត្តម | **ជួន សុភាន់ណារិទ្ធ** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាអគ្គនាយកទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៦. ឯកឧត្តម | **គង់ ផល្លះ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៧. ឯកឧត្តម | **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨. ឯកឧត្តម | **ម៉ុក ប៊ុនឌី** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៩. ឯកឧត្តម | **ម៉ាន់ ដានី** | អគ្គាធិការនៃអគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១០. លោក | **ម៉ាង សុតារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១. លោកស្រី | **ឈុន ដាលីន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២. លោក | **ប៉ែន ទុត្ថា** | ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៣. លោក | **ដេត ទាសនា** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៤. លោក | **សូរ សារិទ្ធ** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥. លោក | **ស្វាយ គុណ្ណាវុធ** | ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៦. លោក | **អ៊ុំ ភក្តដា** | ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៧. លោក | **ខៀវ ណារ៉ា** | ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

១៨. លោក **សេង ខៀង** អនុប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១៩. លោក **អៀង ស៊ុនសុវត្ថិសាល** ជំនួយការឯកឧត្តម **អៀង ស៊ុនលី** សមាជិក។

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា មានតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំការវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា
- រៀបចំលក្ខន្តិកៈរបស់ទូរគមនាគមន៍កម្ពុជាឡើងវិញ ដើម្បីកំណត់មុខងារនិងភារកិច្ចថ្មី ស្របតាមគោលដៅកែទម្រង់
- កំណត់ឡើងវិញនូវទ្រព្យសម្បត្តិរបស់ទូរគមនាគមន៍កម្ពុជា ជាអាទិ៍ អចលនវត្ថុ ចលនវត្ថុ ទ្រព្យសកម្ម ។ល។ ព្រមទាំងបំណុលទាំងអស់របស់ទូរគមនាគមន៍ ជាអាទិ៍ បំណុលដែលជំពាក់តតិយជន និងបំណុលដែលតតិយជនជំពាក់
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូន **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និង **ប្រមុខរាជរដ្ឋាភិបាល**
- បំពេញភារកិច្ចផ្សេងៗទៀតដែល **ប្រមុខរាជរដ្ឋាភិបាល** ប្រគល់ជូន។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួសបាន។ ក្នុងករណីចាំបាច់ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** អាចកោះប្រជុំគណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា។

ប្រធានគណៈកម្មការអន្តរក្រសួងចំពោះកិច្ច អាចអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតមកចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា អាចបង្កើតគណៈកម្មការបច្ចេកទេសមួយចំនួន តាមការចាំបាច់ ដែលមានសមាសភាពចូលរួមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង/ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការបំពេញតួនាទីនិងភារកិច្ច ដូចមានចែងក្នុងសេចក្ដីសម្រេចនេះ។

**ប្រការ៦ .-**

គណៈកម្មការអន្តរក្រសួងចំពោះកិច្ចទទួលបន្ទុកវាយតម្លៃស្ថានភាពរបស់ទូរគមនាគមន៍កម្ពុជា អាចស្នើសុំកិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការពីគ្រប់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងក្របខណ្ឌនៃការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងចំពោះកិច្ចអាចស្នើសុំ **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដើម្បីកោះប្រជុំពិភាក្សារកដំណោះស្រាយចំពោះកិច្ចការទាំងឡាយណាដែលមិនអាចដោះស្រាយបានក្នុងកម្រិតបច្ចេកទេស។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៤៨ សរណន

## សារាចរណែនាំ

## ស្ដីពី

## ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣

### ១- សេចក្ដីផ្ដើម

១-មាត្រា ៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាលគឺៈ (១)-ដំណាក់កាលទី ១ គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, (២)-ដំណាក់កាលទី ២ គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង (៣)-ដំណាក់កាលទី ៣ គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ ដូចនេះ ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣, រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដើម្បីផ្ដល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខ័ណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ ២០២៣ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្ដប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជារដ្ឋបាលថ្នាក់ជាតិ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។ ដូច្នេះ សារាចរណែនាំនេះនឹងដាក់ចេញនូវក្របខ័ណ្ឌ និងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាដោយផ្អែកលើលទ្ធភាពជាក់ស្ដែងនៃថវិកាជាតិ, អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។

២-ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងស័ក្ដសិទ្ធិភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្ដសិទ្ធិភាពនៃការអនុវត្តចំណាយ ទាំងកម្រិតបច្ចេកទេស និងកម្រិតប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

៣-ក្នុងឆ្នាំ ២០២១, ស្របគ្នានឹងការងើបឡើងវិញនៃសេដ្ឋកិច្ចសកល, សេដ្ឋកិច្ចកម្ពុជាមានកំណើនឡើងវិញក្នុងអត្រាទាប ៣,០% ក្នុងឆ្នាំ ២០២១ បន្ទាប់ពីកំណើនអវិជ្ជមាន ៣,១% ក្នុងឆ្នាំ ២០២០ ដែលគាំទ្រដោយការអនុវត្តវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល, ការងើបឡើងវិញក្នុងល្បឿនលឿននៃវិស័យឧស្សាហកម្ម និងកំណើនល្អប្រសើរនៃវិស័យកសិកម្ម។ កំណើននេះបានធ្វើឱ្យ ផសស សម្រាប់មនុស្សម្នាក់ស្មើនឹង ១ ៦៥៩ ដុល្លារអាម៉េរិក និងអត្រាអតិផរណាជាមធ្យមប្រចាំឆ្នាំស្ថិតក្នុងរង្វង់ ២,៩% ខណៈដែលអត្រាប្តូរប្រាក់ជាមធ្យមប្រមាណ ៤ ០៦៨ រៀល ក្នុងមួយដុល្លារអាម៉េរិក។ តាមការវាយតម្លៃជារួមបង្ហាញថា វិស័យឧស្សាហកម្មសម្រេចបានកំណើនល្អប្រសើរក្នុងអត្រា ៨,៦% ទោះបីជាទទួលរងការបន្ទចបង្អាក់ពី "ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ" ដែលគាំទ្រដោយការងើបឡើងវិញនៃអនុវិស័យកាត់ដេរ និងការបន្តកំណើនល្អប្រសើរនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ស្របពេលដែលអនុវិស័យសំណង់ក៏បានងើបឡើងវិញ តែក្នុងល្បឿនយឺត។ ទន្ទឹមនេះ, វិស័យកសិកម្មក៏សម្រេចបានកំណើនល្អប្រសើរក្នុងអត្រា ១,១% ដែលរុញច្រានដោយកំណើនល្អនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ ក្នុងខណៈដែលអនុវិស័យនេសាទមានកំណើនធ្លាក់ចុះ។ ចំណែកឯ វិស័យសេវាកម្មបន្តមានកំណើនអវិជ្ជមាន ១,៩% ដោយសារការបន្តធ្លាក់ចុះនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន។

៤-សម្រាប់ទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈវិញ, ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបន្តដាក់សម្ពាធដល់ថវិកាជាតិគួរឱ្យកត់សម្គាល់។ ជាក់ស្តែង, ការប្រមូលចំណូលក្នុងស្រុកសម្រាប់ឆ្នាំ ២០២១ សម្រេចបានប្រមាណ ២០,៥៣% នៃ ផសស ពោលគឺមានការថមថយប្រមាណ -៤,៦% ធៀបនឹងលទ្ធផលឆ្នាំ ២០២០ ដោយសារការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ស្របពេលដែលរាជរដ្ឋាភិបាលបន្តអនុគ្រោះពន្ធ និងកាតព្វកិច្ចមិនមែនសារពើពន្ធដល់វិស័យមួយចំនួនដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនេះ។ ចំពោះការអនុវត្តចំណាយក្នុងឆ្នាំ ២០២១ វិញ គឺមានទំហំធំឡើងដល់ទៅ ៣១,៥៩% នៃ ផសស សមាមាត្រនឹង ១០៩,០% នៃច្បាប់ថវិកា ពោលគឺកើនឡើង ១១,១% ធៀបនឹងឆ្នាំ ២០២០។ ជាលទ្ធផល, ជាមួយនឹងការកើនឡើងនូវចំណាយអន្តរាគមន៍យ៉ាងគំហុក ខណៈដែលចំណូលមានការធ្លាក់ចុះ, ឱនភាពថវិកាក្នុងឆ្នាំ ២០២១ បានកើនឡើងខ្ពស់រហូតដល់ទៅ -១១,០៦% នៃ ផសស ។

៥-ដោយឡែក សម្រាប់ឆ្នាំ ២០២២, ស្របគ្នានឹងនិន្នាការកើនឡើងនៃសេដ្ឋកិច្ចសកល, សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងទុកថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៥,៤% ដែលបន្តគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការសកល ទោះបីជារងការប៉ះទង្គិចពីការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ សង្គ្រាមនេះ បានបង្កផលប៉ះពាល់ដោយប្រយោលដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការកើនឡើងថ្លៃទំនិញគ្រប់ប្រភេទ ពិសេសប្រេងឥន្ធនៈ និងវត្ថុធាតុដើមកសិកម្ម រួមមាន ជី និងថ្នាំសម្លាប់សត្វល្អិត ជាដើម។ ទន្ទឹមនេះ, ការកើនឡើងថ្លៃជារួម បានបង្កផលប៉ះពាល់ដល់សកម្មភាពចាយវាយ និងការប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ ទោះជាយ៉ាងនេះក្តី, ផលប៉ះពាល់នៃសង្គ្រាមនេះមកលើសេដ្ឋកិច្ចកម្ពុជាគឺមានទំហំតូច ដោយហេតុថាទំនាក់ទំនងសេដ្ឋកិច្ចដោយផ្ទាល់រវាងកម្ពុជាជាមួយនឹងប្រទេសជម្លោះទាំងពីរមានកម្រិតទាប ដែលត្រូវបានប៉ះប៉ូវមកវិញមួយផ្នែកធំដោយការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបានធ្វើឱ្យកម្ពុជាបង្កើតបាននូវ **ភាពស៊ាំសហគមន៍** ជាមូលដ្ឋានសំខាន់សម្រាប់ការបើកប្រទេសឡើងវិញ និងបានអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពវិញ។

៦-ដូចនេះ ឆ្នាំ ២០២៣ ដែលជាឆ្នាំចុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា និងក្នុងបរិបទនៃការគិតគូរស្តារកំណើនសេដ្ឋកិច្ច តាមរយៈការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី (new normal) ព្រមជាមួយនឹងភាពធូរស្រាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបានអនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស, ទាមទារឱ្យរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការដាក់ចេញ និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការអន្តរាគមន៍សមស្រប និងទាន់ពេលវេលា ដោយបោះជំហានលើគន្លងអភិវឌ្ឍន៍ថ្មីផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល និងបន្តគ្រប់គ្រងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ និងការកែទម្រង់ជារចនាសម្ព័ន្ធដើម្បីឈានឆ្ពោះទៅសម្រេចបាននូវភាពធន់នឹងវិបត្តិ ដោយផ្តោតសំខាន់លើ៖ (១)-ការពង្រឹងសមត្ថភាពស្ថាប័នប្រកបដោយឆន្ទៈនយោបាយខ្ពស់ក្នុងទិសដៅជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងកសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ, (២)-ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចដែលតូចចង្អៀត និងបង្កើនភាពប្រកួតប្រជែង ដោយការធ្វើបរិវត្តកម្មឌីជីថល, ការគាំទ្រនិងផ្តល់ការលើកទឹកចិត្តដល់អាជីវកម្មក្នុងស្រុក, ការបង្កបរិយាកាសងាយស្រួលដល់ការធ្វើធុរកិច្ច, ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម, ការបន្តតម្រង់ទិសធនធានឱ្យកាន់តែចំគោលដៅអភិវឌ្ឍន៍នៃវិស័យជំរុញកំណើនជាអាទិភាព និង (៣)-ការកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និងមានភាពឆ្លើយតបខ្ពស់។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដូចខាងក្រោម៖

## ២- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣

### ២.១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣

៧-សម្រាប់ឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើន ក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកការបន្តនិន្នាការល្អប្រសើរនៃតម្រូវការសកល និងទំនុកចិត្តវិនិយោគ ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត និងអាចគ្រប់គ្រងបាន។ ទន្ទឹមនេះ, "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" នឹងបន្តរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងការបង្កើនតម្លៃបន្ថែមទៀត ដល់អនុវិស័យជំរុញកំណើនដែលមានស្រាប់ ក៏ដូចជាលើកកម្ពស់អនុវិស័យសក្តានុពល ដែលជាចន្ទល់កំណើនថ្មី រួមមានអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យគមនាគមន៍ ព្រមទាំងការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានគិតគូរបង្កើនកញ្ចប់អន្តរាគមន៍ ជាពិសេសផ្នែកសង្គម និងសេដ្ឋកិច្ច ដើម្បីជួយកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងអតិផរណា និងការបង្កើនការវិនិយោគក្នុងស្រុក ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតការងារជូនប្រជាជនផងដែរ។ ផ្អែកលើសមិទ្ធកម្មខាងលើនេះ កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ ត្រូវបានគាំទ្រដោយ៖

- វិស័យកសិកម្ម ត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងរង្វង់ ១,១% ក្នុងឆ្នាំ ២០២៣ ដោយសារកំណើនរឹងមាំនៃអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យដំណាំ ស្របពេលដែលអនុវិស័យនេសាទរំពឹងថានឹងបន្តដើបឡើងវិញសន្សឹមៗ។ អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានឹងបន្តរក្សាបានកំណើនល្អប្រសើរក្នុងរង្វង់



ថ

១,០% សម្រាប់ឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវកំណើនផលិតកម្មចិញ្ចឹមសត្វ ពិសេសផលិតកម្មជ្រូក ដើម្បីឆ្លើយតបនឹងការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា។ ចំណែកឯ **អនុវិស័យដំណាំ** ត្រូវបាន ព្យាករថានឹងមានកំណើន ១,៦% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវកំណើននៃការនាំចេញផលិតផលកសិកម្ម ពិសេសដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដែលនឹងបន្តជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមាន "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន", "កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ" និង "កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)" ជាដើម គួបផ្សំនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល ពិសេសការបន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការនាំចូលវត្ថុធាតុដើមកសិកម្ម និងការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក។ **អនុវិស័យនេសាទ** ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រា ០,៦% ក្នុងឆ្នាំ ២០២៣ ក្រោមការរំពឹងទុកនូវការកើនឡើងសន្សឹមៗនៃផលចាប់ត្រីទឹកសាប និងផលិតកម្មវារីវប្បកម្ម ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ *ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្មជារួម នៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ រួមមានៈ កំណើនទាបនៃផលិតភាពដី និងផលិតភាពពលកម្ម, ថ្លៃដើមផលិតកម្មខ្ពស់, ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ភាពទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម, និងកង្វះការវិនិយោគលើការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពល ដើម្បីទាញយកតម្លៃបន្ថែម។*

• **វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៩,២% ក្នុងឆ្នាំ ២០២៣ ដែលកំពុងវិលត្រឡប់មករកនិន្នាការកំណើនមុនពេលវិបត្តិជំងឺកូវីដ-១៩ ដែលគាំទ្រដោយការបន្តភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ដែលនឹងបន្តជំរុញកំណើននៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ក្នុងខណៈដែលអនុវិស័យសំណង់ត្រូវបានរំពឹងថានឹងបន្តងើបឡើងក្នុងល្បឿនយឺត ដោយសារការងើបឡើងវិញសន្សឹមៗនៃលំហូរទុនវិនិយោគ។ **អនុវិស័យកាត់ដេរ** ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនរឹងមាំក្នុងអត្រា ៨,១% ក្នុងឆ្នាំ ២០២៣ ដែលគាំទ្រដោយស្ថិរភាពនៃកត្តាក្នុងស្រុកដែលសម្រេចបានតាមរយៈអត្រាចាក់វ៉ាក់សាំងខ្ពស់របស់កម្មករ-និយោជិត, ភាពល្អប្រសើរនៃកត្តាខាងក្រៅ ជាពិសេសការរំពឹងទុកនូវការបន្តកើនឡើងតម្រូវការពីទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និងការបន្តទទួលបានការបង្វែរការបញ្ជាទិញពីប្រទេសក្នុងតំបន់ ជាពិសេសប្រទេសមីយ៉ាន់ម៉ា។ **អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនល្អប្រសើរក្នុងរង្វង់ ១៣,៣% ក្នុងឆ្នាំ ២០២៣ ដែលគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ពិសេសទីផ្សារសហរដ្ឋអាមេរិក ស្របជាមួយនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមានៈ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ, ព្រមទាំងការអនុវត្ត "ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា"។ **អនុវិស័យសំណង់** ត្រូវបានព្យាករថានឹងបន្តងើបឡើងវិញក្នុងអត្រា ៧,២% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវការងើបឡើងវិញនៃលំហូរវិនិយោគទុនពីបរទេស សម្រាប់សំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ខណៈដែលសំណង់លំនៅឋានថ្លៃទាប និងមធ្យម រំពឹងថានៅបន្តរក្សាកំណើនល្អប្រសើរ ដោយសារការកើនឡើងនៃតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងការរៀបចំគ្រួសារ ស្របគ្នានឹងនិន្នាការនៃការកើនឡើងការវិនិយោគក្នុងស្រុក។ *ទោះជាយ៉ាងនេះក្តី, វិស័យឧស្សាហកម្មជារួម នៅបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន ក្នុងនោះ ការកើនឡើងនូវការប្រកួតប្រជែងពីប្រទេសជិតខាង, ការបាត់បង់នូវការបង្វែរការបញ្ជាទិញ, ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធ និងភាពមានកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងផលិតកម្ម សម្រាប់អនុវិស័យកាត់ដេរ។ ចំពោះអនុវិស័យកម្មន្តសាលមិនមែន*

*កាត់ដេរវិញ ក៏ជួបបញ្ហាជារចនាសម្ព័ន្ធមួយចំនួន រួមមានៈ បញ្ហាកង្វះវត្ថុធាតុដើមក្នុងស្រុក, កង្វះកម្លាំងពលកម្ម, ជំនាញបច្ចេកទេស, ថ្លៃអគ្គិសនីខ្ពស់, កង្វះប្រភេទអាជីវកម្មធុនតូចនិងមធ្យម (Missing Middle), និងភាពមានកម្រិតក្នុងការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងតំបន់។ ទន្ទឹមនេះ ការបន្តកើនឡើងខ្ពស់នៃឥណទានផ្តល់ទៅវិស័យសំណង់ក្នុងស្រុក គឺជាហានិភ័យមួយសម្រាប់អនុវិស័យសំណង់ និងវិស័យហិរញ្ញវត្ថុទាំងមូលផងដែរ។*

• វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងងើបឡើងវិញជាសន្សឹមៗក្នុងអត្រា ៦,៦% ក្នុងឆ្នាំ ២០២៣ ដោយសារការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងការបន្តនិន្នាការកើនឡើងនៃអនុវិស័យគាំទ្រផ្សេងៗទៀត រួមមានៈ អនុវិស័យលក់ដុំ-រាយ, អនុវិស័យអចលនទ្រព្យ និងអនុវិស័យដឹកជញ្ជូន និងគមនាគមន៍។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រា ២៣,៤% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ ក៏ប៉ុន្តែក្នុងល្បឿនយឺត ក្នុងខណៈដែលចំនួនភ្ញៀវទេសចរជាតិ ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងល្បឿនមួយលឿនជាង ដោយសារការបង្កើតបាននូវភាពស៊ាំសហគមន៍ ដែលបានអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច ដំណើរការឡើងវិញ និងត្រលប់ទៅរកនិន្នាការធម្មតាក្នុងគន្លងប្រក្រតីភាពថ្មី។ អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនក្នុងអត្រា ៦,៧% ក្នុងឆ្នាំ ២០២៣ ដោយសារការងើបឡើងវិញជាបណ្តើរៗនៃអនុវិស័យដែលជាប្រភពចំណូលរបស់ប្រជាជន។ អនុវិស័យអចលនទ្រព្យ ត្រូវបានព្យាករថានឹងបន្តងើបឡើងវិញក្នុងអត្រា ៥,២% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកនូវការងើបឡើងវិញនៃសកម្មភាពទិញ-លក់ និងជួលអចលនទ្រព្យថ្លៃខ្ពស់ រួមមានៈ ខុនដូ និងអាផាតមិន ស្របពេលដែលការវិនិយោគ និងតម្រូវការក្នុងស្រុកលើអចលនទ្រព្យផ្អែកលំនៅឋានថ្លៃទាប និងមធ្យម ត្រូវបានរំពឹងទុកថានៅបន្តរក្សាកំណើនល្អ។ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៧,១% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពដឹកជញ្ជូន ខណៈដែលការប្រើប្រាស់ប្រព័ន្ធឌីជីថលមានការកើនឡើង ស្របទៅនឹងនិន្នាការនៃការផ្លាស់ប្តូរបៀបរស់នៅរបស់ប្រជាជន និងសកម្មភាពអាជីវកម្មក្នុងគន្លងប្រក្រតីភាពថ្មី។ *ទោះជាយ៉ាងនេះក្តី, វិស័យសេវាកម្មជារួម នឹងជួបបញ្ហាប្រឈមមួយចំនួន ក្នុងនោះ៖ (១)-អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ជួបប្រឈមនឹង៖ ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សមត្ថភាពស្ថាប័ន និងការធ្វើពិពិធកម្មគោលដៅ, ផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការបាត់បង់តម្លៃបន្ថែមសេដ្ឋកិច្ច ដោយសារភាពមានកម្រិតនៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ, (២)-អនុវិស័យលក់ដុំ-រាយ អាចប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ រួមមានៈ ការវិវត្តនៃវីរុសបំប្លែងខ្លួនថ្មី និងការបន្តកើនឡើងថ្លៃ ដែលអាចបន្តជាក់សម្ពាធដល់អាជីវកម្មក្នុងស្រុក និងប៉ះពាល់ដល់សកម្មភាពប្រើប្រាស់ក្នុងស្រុក, (៣)-អនុវិស័យអចលនទ្រព្យ នៅតែប្រឈមនឹងហានិភ័យខ្ពស់ស្រដៀងគ្នាទៅនឹងអនុវិស័យសំណង់ ដោយហេតុថាអនុវិស័យអចលនទ្រព្យមានទំនាក់ទំនងខ្ពស់ជាមួយនឹងវិស័យហិរញ្ញវត្ថុក្នុងនិងក្រៅប្រព័ន្ធធនាគារ (កម្ចីផ្តល់ដោយក្រុមហ៊ុនអភិវឌ្ឍន៍) និង (៤)-អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ក៏បន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមាន ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក ខណៈដែលថ្លៃសេវាអ៊ីនធឺណិតនៅមានកម្រិតខ្ពស់ ធៀបនឹងប្រទេសក្នុងតំបន់។*

• ក្នុងឆ្នាំ ២០២២, អតិផរណាត្រូវបានប៉ាន់ស្មានថាអាចកើនឡើងក្នុងរង្វង់ ៥,០% ដោយសារការកើនឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត បណ្តាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ សម្រាប់ឆ្នាំ ២០២៣, អតិផរណាត្រូវបានរំពឹងថានឹងថមថយមកវិញក្នុងរង្វង់ ២,៥% ដោយសារការរំពឹងទុកនូវការវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេង និងទំនិញផ្សេងៗទៀត ក៏ដូចជាសកម្មភាពសេដ្ឋកិច្ច។ អត្រាប្តូរប្រាក់រំពឹងថានឹង

ស្ថិតក្នុងរង្វង់ជាមធ្យមប្រចាំឆ្នាំប្រមាណ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល ។

• ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងរួមតូចមកវិញ ក្នុងទំហំប្រមាណ ២៦,៨% នៃ ផសស ក្នុងឆ្នាំ ២០២២ ធៀបនឹង ៤៥,៤% នៃ ផសស ឆ្នាំ ២០២១ ក្រោមការរំពឹងទុកនូវការត្រឡប់ទៅរកប្រក្រតីភាពនៃសមតុល្យពាណិជ្ជកម្ម ក្នុងខណៈដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បញ្ញើពីក្រៅប្រទេស (remittance) ក៏ត្រូវបានរំពឹងថានឹងងើបឡើងវិញសន្សឹមៗ ស្របតាមភាពស្រាកស្រាន្តនៃស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ជាបណ្តើរៗ។ សម្រាប់ឆ្នាំ ២០២៣, ឱនភាពគណនីចរន្តរំពឹងថានឹងបន្តរួមតូចក្នុងរង្វង់ប្រមាណ ១៤,១% នៃ ផសស ដោយសារការរំពឹងទុកនូវការបន្តកើនឡើងនៃការនាំចេញ និងការបន្តនិន្នាការងើបឡើងនៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ។ ជាមួយគ្នានេះ, រំហូរវិនិយោគផ្ទាល់ពីបរទេសសម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងងើបឡើងក្នុងរង្វង់ ១២,០% នៃ ផសស និង ១១,៦% នៃ ផសស រៀងគ្នា ដោយសារការបន្តកើនឡើងនូវទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែអំណោយផលរបស់កម្ពុជា ក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននូវខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់ តំបន់ និងសកល ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត។ ជាលទ្ធផល, ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២១ ២៧១ និង ២២ ១៥៥ លានដុល្លារអាម៉េរិក ដែលធានាការនាំចូលបានប្រមាណ ៧,៧ និង ៧,៦ ខែ ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣ រៀងគ្នា។

៨-ជារួម ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣ ត្រូវបានរៀបចំឡើងក្នុងបរិបទនៃការគិតគូរសម្រេចឱ្យបាននូវការរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាជនក្នុងការរស់ជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។ ជាក់ស្តែង ក្របខ័ណ្ឌនេះ មានគោលដៅគាំទ្រការជំរុញកំណើនសេដ្ឋកិច្ចឱ្យសម្រេចបានក្នុងរង្វង់ ៦,៦% ជាមួយនឹងអត្រាអតិផរណាទាបដែលអាចគ្រប់គ្រងបានក្នុងរង្វង់អត្រាប្រមាណ ២,៥% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាម៉េរិក។

**២.២- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២៣**

៩-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី៦ នៃរដ្ឋសភា មានចរិតជា **ថវិកាពិគ្រោះកម្មចំគោលដៅ** ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និងដោយផ្តល់**អាទិភាពទី១ ដល់មនុស្ស** និងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានចែងក្នុង"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤", ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងជាពិសេសក្នុង "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣"។ ក្នុងន័យនេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣ មានគោលបំណងសំខាន់ៗ ដូចតទៅ៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន;

- បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកកំណើនសក្តានុពល តាមរយៈការបន្តអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣,
- ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា ដែលអាចឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតមានដោយចៃដន្យ,
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញ ប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ,
- ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងកម្រិតសមស្រប ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ,
- ដំឡើងប្រាក់សោធន និង កាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី ជូនដល់ អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ,
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធ,
- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព,
- បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្ត ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច ។
- ធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ ២០២៣ ព្រមទាំងការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី ៥។

១០-ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ ២០២៣ ដូចខាងក្រោម៖

### ២.២.១- ក្របខ័ណ្ឌចំណូលថវិកាឆ្នាំ ២០២៣

១១-គម្រោងចំណូលថវិកាឆ្នាំ ២០២៣ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំណូលសរុបក្នុងប្រទេសថវិកាជាតិសម្រាប់ឆ្នាំ ២០២៣ គ្រោងសម្រេចឱ្យបាន ២១,៨៩% នៃ ផសស គឺកើនឡើង ០,៦២ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ១២,៣% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២២) ក្នុងនោះ៖

• ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ២១,៦៤% នៃ ផសស គឺកើនឡើង ១,៤៥ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ១៧,០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៨,៤៨% នៃ ផសស គឺថយចុះ ០,១៦ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២, ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ១១,០% នៃ ផសស គឺកើនឡើង ១,៥ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ២៦,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២, និងចំណូលមិនមែនសារពើពន្ធ ត្រូវគ្រោងសម្រេចឱ្យបាន ២,១៦% នៃ ផសស គឺកើនឡើង ០,១០ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ១៤,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២។

• ចំណូលមូលធនក្នុងប្រទេស ត្រូវសម្រេចឱ្យបាន ០,២៥% នៃ ផសស គឺថយចុះ ៧៤,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២។

• ចំណែកឯ ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ គ្រោងសម្រេចឱ្យបាន ៤,៧០% នៃ ផសស គឺថយចុះ ០,១៣ ពិន្ទុភាគរយ នៃ ផសស ឬកើនឡើង ៦,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ហើយមូលនិធិទ្រទ្រង់ថវិកាគ្រោងសម្រេចឱ្យបាន ០,៩៨% នៃ ផសស។

១២-ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។

**ក.១- ផ្នែកចំណូលពន្ធដារ**

១៣-វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៣ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តនានានិងដាក់ចេញនូវវិធានការចាំបាច់បន្ថែមទៀតដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩,
- ពង្រឹងការប្រមូលចំណូលតាមវិស័យដែលនៅមានសក្តានុពល ដូចជា វិស័យសំណង់, វិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យផលិតស្រាបៀរ, ភេសជ្ជៈ និងថ្នាំជក់ ជាដើម,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, និង ពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា,
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម ដែលមានភាពប្រឡាក់ក្រឡា, ស្វ័យប្រវត្តិកម្មពេញលេញ និង ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ, និង
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ ។

**ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ**

១៤-វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៣ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម ៖

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម,
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់ធុរជន,
- បន្តបង្កើនចំនួនធុរជនមានអនុលោមភាពខ្ពស់ និងជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (Authorized Economic Operator- AEO), និង
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ និងតភ្ជាប់បញ្ជរតែមួយជាតិកម្ពុជាទៅនឹងបញ្ជរតែមួយអាស៊ាន។

**ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ**

១៥-ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន៖

- ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ,
- ជំរុញការដាក់ឱ្យអនុវត្ត និងពង្រីកវិសាលភាពប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) នៅរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់,
- ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើទំហំក្នុងកិច្ចសន្យាស្របតាមគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល,
- ជំរុញការបង់ចំណូលដីសម្បទានសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធអេឡិចត្រូនិក និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ច ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពិនិត្យកែសម្រួលអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីបង់សួយសារ,
- បន្តតាមដាន និង គ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈការពិនិត្យលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ជាមួយក្រសួងសាមី និងស្ថាប័នពាក់ព័ន្ធ, និង
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល។

**២.២.២- ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ ២០២៣**

១៦-ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអនុវត្តអន្តរាគមន៍ចាំបាច់នានា គម្រោងចំណាយថវិកាឆ្នាំ ២០២៣ ត្រូវបានកំណត់ និងវិភាជតាមក្របខ័ណ្ឌរួមដូចខាងក្រោម៖

• ចំណាយសរុបថវិការដ្ឋ នៅឆ្នាំ ២០២៣ នឹងកំណត់ក្នុងរង្វង់ ២៩,៤៣% នៃ ផសស គឺកើនឡើង ០,៥៨ ពិន្ទុភាគរយនៃ ផសស ឬកើនឡើង ១១,៣% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២២) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,៤៨% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩៥% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ១,០០% នៃ ផសស។

- ចំណាយចរន្តថវិការដ្ឋត្រូវកំណត់ក្នុងកម្រិត ១៧,៦៥% នៃ ផសស គឺកើនឡើង ០,៣២ ពិន្ទុភាគរយ នៃ ផសស ឬកើនឡើង ១១,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ដែលក្នុងនោះ៖
  - ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៤,៤% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៨៥% នៃ ផសស ដោយផ្តោតអាទិភាពទៅលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,
  - ចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៥,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៩,៨១% នៃ ផសស ដោយផ្តោតអាទិភាពទៅលើ៖ (១)-ការបន្តគាំពារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងរៀបចំមូលដ្ឋានសង្គមកម្ពុជាឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពង្រឹងគុណភាព និងការពង្រីកវិសាលភាពនៃវិស័យសុខាភិបាល និងប្រព័ន្ធគាំពារសង្គម; និង (២)-សម្រេចឱ្យបាននូវរាល់គោលដៅអាទិភាពនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា នៅឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិ។

- ចំណាយមូលធនត្រូវបានគ្រោងប្រមាណ ១១,៧៨% នៃ ផសស គឺកើនឡើង ០,២៦ ពិន្ទុភាគរយ នៃ ផសស ឬកើនឡើង ១១,៦% ធៀបនឹងច្បាប់ឆ្នាំ ២០២២ ក្នុងគោលដៅស្តារ និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង បៃតង ក៏ដូចជាពង្រឹងមូលដ្ឋានអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ បន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ ជាពិសេស ជំរុញវិស័យដែលជាចន្ទល់កំណើន និងផលិតភាពសេដ្ឋកិច្ច។

- ចំណាយសរុបថវិកាថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងភាជទៅតាមវិស័យ ដូចខាងក្រោម៖
  - វិស័យរដ្ឋបាលទូទៅ៖ ត្រូវបានគ្រោងប្រមាណ ១,៧៥% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត ពិសេសការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣ និងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា;
  - វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖ ត្រូវបានគ្រោងប្រមាណ ៣,៩១% នៃ ផសស ដោយបន្តផ្តោតលើការគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;

- វិស័យសង្គមកិច្ច៖ ត្រូវបានគ្រោងប្រមាណ ៨,២៥% នៃ ផសស សំដៅបន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការទទួលបានសេវាសុខាភិបាល, ពង្រឹងប្រព័ន្ធសុខភាពសាធារណៈដែលឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, អនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅ តាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩, បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំ, គាំទ្រដល់ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥, និងគោលនយោបាយអាទិភាពផ្សេងៗទៀតលើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន ជាពិសេសការប្រែប្រួលអាកាសធាតុ;
- វិស័យសេដ្ឋកិច្ច៖ ត្រូវបានគ្រោងប្រមាណ ៧,១១% នៃ ផសស ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម, ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរផលិតស្បែកជើងនិងកាបូបកម្ពុជាឆ្នាំ ២០២២-២០២៧, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០. និងការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥, ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីឆ្នាំ ២០២១-២០៣៥;
- ចំណាយផ្សេងៗ៖ ត្រូវបានគ្រោងប្រមាណ ៦,៤៥% នៃ ផសស ដើម្បីធានាបាននូវលទ្ធភាពអន្តរាគមន៍ភ្លាមៗ ក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិនិងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល រួមទាំងការបន្តធ្វើអន្តរាគមន៍ឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ មានជាអាទិ៍ ៖ *ការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ ១ និង ក្រ ២) និង ការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់តែមួយលើកជូនគ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់ក្រីក្រ ដើម្បីទប់ទល់នឹងបញ្ហាអតិផរណា, ការបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម, កម្មវិធីអន្តរាគមន៍លើផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ការធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ ២០២៣។*

• ចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវកំណត់ត្រឹម ១៦,០៩% នៃ ផសស កើនឡើង ១០,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ដែលក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៤,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,២០% នៃ ផសស និងចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៥,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៨,៨៩% នៃ ផសស។

• ចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិ ត្រូវកំណត់ត្រឹម ២,៥៦% នៃ ផសស កើនឡើង ១១,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៦៥% នៃ ផសស និងចំណាយក្រៅបន្ទុកបុគ្គលិក

១,៩១% នៃ ផសស ដែលត្រូវប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបមានប្រមាណ ១,៥៦% នៃ ផសស និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិស្មើនឹង ១,០០% នៃ ផសស។

១៧-ក្នុងក្របខ័ណ្ឌនៃគោលដៅក្បាលនឹងសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចឡើងវិញ, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការដាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២៣ ដូចខាងក្រោម៖

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងការដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩ និងគាំទ្រជីវភាពប្រជាពលរដ្ឋងាយរងគ្រោះដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ,
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និង ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី សម្រាប់ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបាននូវភាពធន់ ប្រកបដោយបរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល,
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ,
- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ពិសេសវិស័យបង្កើនផលិតភាព, ជំរុញការតភ្ជាប់ និង លើកកម្ពស់សមត្ថភាពប្រកួតប្រជែង, និង
- បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់នានា និងគោលនយោបាយអាទិភាព ដោយពង្រឹង៖ (ក)-ការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៣-២០២៥, (ខ)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, (គ)-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥, (ឃ)-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣, (ង)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ និង (ច)-ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥។

### ២.២.៣- ក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ ២០២៣

១៨-ជារួម ការអនុវត្តនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ៣,៩៩% នៃ ផសស និងឱនភាពថវិកាសរុបក្នុងរង្វង់ -៧,៥៤% នៃ ផសស ក្នុងឆ្នាំ ២០២៣។ ដូចនេះ រាជរដ្ឋាភិបាលនឹងត្រូវប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាលសរុប ប្រមាណ ១,៨៦% នៃ ផសស ដើម្បីផ្តល់អាទិភាពដល់ការបន្តគាំពារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយយកមនុស្សជា

អាទិភាពទី១ និងដើម្បីធានាសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗដែលមានចែងក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ច ស្របតាម "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"។

## ៣- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២៣

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ ២០២៣

១៩-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
  - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២២);
  - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

### ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២៣

២០-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ ស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ *ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការកំណត់គោលបំណង និងកត្តាកំណត់ជោគជ័យនៃកម្មវិធី និងអនុកម្មវិធីឱ្យបានល្អ ដើម្បីធានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ជាពិសេសត្រូវកំណត់សូចនាករ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ*

*និងច្បាស់លាស់ ដើម្បីចាប់ផ្ដើមអនុវត្តសាកល្បងថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា "ថវិកាសមិទ្ធកម្ម" ព្រមជាមួយនឹងការចាប់ផ្ដើមអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្ម ចាប់ពីឆ្នាំ ២០២៣ ដែលកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ត្រូវបានកំណត់ជា ៣ កម្រិត៖ (ទី១)- រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នសាមី, (ទី២)- រវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័នសាមី, និង (ទី៣)- រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា ដូចមានភ្ជាប់ជូននូវគំរូកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតនេះ ។ សម្រាប់ការរៀបចំថវិកាឆ្នាំ ២០២៣ ខាងមុខនេះ, ក្រសួង-ស្ថាប័នចំនួន ៧ ត្រូវបានកំណត់ឱ្យអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ដែលរួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល និង ក្រសួងយុត្តិធម៌។ សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២១-គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការដាក់ស្ដែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២១ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២២ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២២-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្ដល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២៣ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយរបស់ខ្លួន ទៅតាម **គោលការណ៍** និង **បណ្ដាវិធានការ** ដូចខាងក្រោម៖

ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖ នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងន័យនេះ ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២៣ ត្រូវអនុវត្តគោលការណ៍លម្អិត ដូចខាងក្រោម៖

- ចំនួនក្របខ័ណ្ឌថ្មី ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ក្នុងឆ្នាំ ២០២២ និងត្រូវបញ្ជាក់អំពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័នអាចស្នើសុំប្រើប្រាស់ថវិកានោះ ដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់ និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ជាពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗ របស់ក្រសួង-ស្ថាប័ន;*
- គ្រោងបៀវត្សមូលដ្ឋាន ដោយផ្អែកតាមចំនួនក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០២២, តាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅក្នុងឆ្នាំ ២០២២។ ចំពោះសន្ទស្សន៍បៀវត្សមូលដ្ឋានត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២២ ដែលមានតម្លៃសន្ទស្សន៍ក្នុង ១ ឯកតា ស្មើនឹង ២ ៥០០រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ;
- គ្រោងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយផ្តល់បន្ថែមជូនចំនួន ១២៧ ៥០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតក្រោម ៧៦០ ០០០ រៀល ចុះ, ផ្តល់បន្ថែមជូន ១២០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ត្រឹមពី ៧៦០ ០០០រៀល ដល់ ៩៩០ ០០០ រៀល, និងផ្តល់បន្ថែមជូន ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារ ក្នុងកម្រិតចាប់ត្រឹមពី ១ ០៣០ ០០ រៀល ឡើង ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ;
- គ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យា មិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២២ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា។ ចំពោះ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោងដំឡើងពី ៦៧០ ០០០ រៀល ទៅដល់ ៧១០ ០០០ រៀល ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ;
- គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន។

ជាមួយគ្នានេះ សម្រាប់ឆ្នាំ ២០២៣ រាជរដ្ឋាភិបាលបានគិតគូរផងដែរលើការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និងជាពិសេស គិតគូរកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តចាស់ និងថ្មីឱ្យបានឆាប់ ដោយបានត្រៀមបម្រុងកញ្ចប់ថវិកាចំនួន ១៦០ ប៊ីលានរៀល នៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល។ គោលការណ៍លម្អិតសម្រាប់អនុវត្តនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

សម្រាប់ការត្រៀមលក្ខណៈអនុវត្តសាកល្បងថវិកាសមិទ្ធកម្មចាប់ពីឆ្នាំ ២០២៣ តទៅ, ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម, គ្រប់ក្រសួង-ស្ថាប័ន ត្រូវចាប់ផ្តើមរៀបចំរបាយការណ៍ចំណាយបន្ទុកបុគ្គលិកដោយបែងចែកទៅតាមកម្មវិធីនីមួយៗ ទៅតាមទម្រង់តារាងលេខ ១១ ដូចមានភ្ជាប់ជូន ដោយយកឆ្នាំនៃការអនុវត្តថវិកា ១ ឆ្នាំមុន (ឆ្នាំ N-1) ជាមូលដ្ឋានសម្រាប់ការរៀបចំ។

ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន) ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ ដូចខាងក្រោម៖

- កំណត់*ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់* ។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ការចំណាយសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។

- *កំណត់ចំណាយមិនប្រចាំ ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខាបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែង។

- ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖ ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៣ ប៉ុន្តែ*កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ នឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ* ។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ មានន័យថា ពិតានចំណាយគោល នៅតែជាកម្មវត្ថុសម្រាប់ការពិភាក្សានៅពេលចរចាថវិកា ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ក៏ដូចជាដើម្បីសន្សំសំចៃថវិកាសម្រាប់បំពេញតម្រូវការចំណាយចាំបាច់ថ្មី។

- មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត, សម្រាប់ឆ្នាំ ២០២៣ មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹងកម្រិតអតិបរមានៃទំហំពិតានចំណាយគោល។ ក៏ប៉ុន្តែ *កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះ* នឹងមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២១ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២២ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធិកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍។ កិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេនគឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកាត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ ២០២២ ហើយលែងត្រូវការនៅក្នុងឆ្នាំ ២០២៣ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០២២។ លើសពីនេះ ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថាលែងមានសារៈសំខាន់ ដូចជា សកម្មភាពចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្ម និងពិព័រណ៍ទេសចរមួយចំនួនដែល

លែងមានភាពចាំបាច់។ ក្នុងន័យនេះ ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ ដែលត្រូវអនុវត្ត និងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងមានយុត្តការណ៍អំពីភាពចាំបាច់ និងបន្ទាន់ មានការពន្យល់ និងផ្តល់អំណះអំណាងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកញ្ចប់ថវិកាដែលកំណត់ក្នុងពិតានចំណាយគោល ចាំបាច់ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តិការណ៍ស្តីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានការកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែមសម្រាប់ពង្រឹង ការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុ នៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្តែង។

- ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុងក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុងក្រសួង-ស្ថាប័នដដែល ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញមួយ ទៅមន្ទីរជំនាញមួយទៀតនៃក្រសួង-ស្ថាប័នតែមួយ ក៏ដូចជាពីមន្ទីរនៃរដ្ឋបាលខេត្តមួយ ទៅមន្ទីរនៃរដ្ឋបាលខេត្តមួយទៀត ក្នុងក្របខ័ណ្ឌនៃវិស័យចំណាយតែមួយ។

គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក ២១) និងចំណាយជួសជុល ស្ពាន និង ថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១)៖

- ក្រសួងដែលទទួលបានចំណាយវិនិយោគជាទៀងទាត់ រួមមាន៖ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី ព្រមទាំងត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេលវេលា ដើម្បីស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល សម្រាប់ជាមូលដ្ឋាននៃការរៀបចំបញ្ជីគម្រោងសង្ខេប ដែលនឹងត្រូវវេចខ្ចប់ជាមួយនឹងចំណាយចរន្តនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។ ចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលត្រូវទទួលបានថវិកាជំពូក ២១ សម្រាប់គម្រោងវិនិយោគផ្ទាល់ ក៏ត្រូវចាប់ផ្តើមធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និងអនុកម្មវិធីផងដែរ សម្រាប់ជាមូលដ្ឋានស្នើសុំ ការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សា តាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោងដែលមានចែងនៅក្នុងសារាចរនេះ។

- សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ។

- ការគ្រោងចំណាយវិនិយោគសម្រាប់គម្រោងសាងសង់ ស្ពាន ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ ត្រូវផ្អែកលើគោលការណ៍កំណត់អាទិភាព ដូចខាងក្រោម៖

- *វិស័យផ្លូវថ្នល់*
    - ✓ **អាទិភាពទី១៖** ជួសជុល ស្ពាន និងថែទាំផ្លូវជាតិគ្រប់ប្រភេទ ដើម្បីធានាចីរភាពនៃប្រព័ន្ធគមនាគមន៍ និងចរាចរ និងទ្រទ្រង់ដង្ហើមសេដ្ឋកិច្ច។
    - ✓ **អាទិភាពទី២៖** ជួសជុល ស្ពាន និងថែទាំផ្លូវខេត្ត និងផ្លូវជនបទសំខាន់ៗ ដែលមានលក្ខណៈជាឆ្អឹងខ្នងនៃប្រព័ន្ធគមនាគមន៍ ដែលបម្រើឱ្យការដឹកជញ្ជូន និងចរាចរនៅកម្រិតមូលដ្ឋាន កម្រិតតំបន់ និង កម្រិតជាតិ។
    - ✓ **អាទិភាពទី៣៖** គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី។
    - ✓ **អាទិភាពទី៤៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បញ្ចប់ ឬគម្រោងដែលមានចរិតពហុឆ្នាំ និងមានប្រសិទ្ធភាពខ្ពស់ រួមទាំងគម្រោងខូចខាតដែលបណ្តាលមកពីទឹកជំនន់។

- ✓ **អាទិភាពទី៥៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។

- *វិស័យធារាសាស្ត្រ*
  - ✓ **អាទិភាពទី១៖** ជួសជុល ស្តារ និងថែទាំប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ ជាពិសេស ប្រព័ន្ធធារាសាស្ត្រដែលបានស្ថាបនារួចដោយថវិកាជាតិ ឬថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។
  - ✓ **អាទិភាពទី២៖** ស្ថាបនាប្រឡាយមេ និង/ឬប្រឡាយរងបន្ថែម ដើម្បីពង្រីកឱ្យអស់សក្តានុពលគម្រោងប្រព័ន្ធធារាសាស្ត្រធំៗដែលត្រូវបានស្ថាបនារួចដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា។
  - ✓ **អាទិភាពទី៣៖** ស្ថាបនាបន្តប្រព័ន្ធធារាសាស្ត្រមិនទាន់អនុវត្តចប់ ដែលមានចរិតពហុឆ្នាំ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យក្លាយជាប្រព័ន្ធធារាសាស្ត្រមានសក្តានុពលពេញលេញ។ គម្រោងខូចខាត ដែលបណ្តាលមកពីទំកដំនន់ឬគ្រោះធម្មជាតិ។
  - ✓ **អាទិភាពទី៤៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។
- *វិស័យអប់រំ*
  - ✓ **អាទិភាពទី១៖** គម្រោងដែលមានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
  - ✓ **អាទិភាពទី២៖** គម្រោងអភិវឌ្ឍន៍សាលារៀនជំនាន់ថ្មី (STEM) ឬស្ថាប័នអប់រំបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាសេដ្ឋកិច្ចឌីជីថល
  - ✓ **អាទិភាពទី៣៖** គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ យុវជន និងកីឡា នៅតាមបណ្តារាជធានី-ខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- *វិស័យសុខាភិបាល*
  - ✓ **អាទិភាពទី១៖** គម្រោងដែលមានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
  - ✓ **អាទិភាពទី២៖ ផ្តល់អាទិភាពដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល និងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** ដើម្បីលើកកម្ពស់គុណភាព និងកែលម្អសេវាសុខភាពសាធារណៈ មានដូចជា៖ មន្ទីរពេទ្យបង្អែក, អគារពិនិត្យសម្រាកព្យាបាលជម្ងឺ, មណ្ឌលសុខភាព, ប៉ុស្តិ៍សុខភាព, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ព្រមទាំងឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈបរិក្ខារពេទ្យនានា។

**ឃ-ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍៖** ក្រសួង-ស្ថាប័នចំនួន ៩ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) និងថវិកាជំពូក ៦១ (ការងារជួសជុល និងថែទាំ) ព្រមទាំងក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២៣-២០២៥) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

**២៣-ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២៣ របស់ខ្លួនចំនួនពីរច្បាប់ (១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ១ ច្បាប់ទៀត បញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

**២៤-ការរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

២៥-ដោយឡែកចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុល ស្តារ និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១) ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាន និងកំពុងអនុវត្តជាធរមាន។

២៦-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០២១ មកក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២៣ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២១ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២២ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២៣។*

២៧-ទន្ទឹមនេះ ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២២ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២៣ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្តដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,
- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

២៨-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

### ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៣

២៩-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីសប្តាហ៍ទី ២ នៃខែ កក្កដា រហូតដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សា និងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីធ្វើការបូកសរុបគម្រោងចំណូល-ចំណាយរៀបចំជាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ដាក់ជូនគណៈរដ្ឋមន្ត្រី នៅក្នុងសប្តាហ៍ទី ១ នៃខែ តុលា ឆ្នាំ ២០២២ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយដាក់ជូនរដ្ឋសភាឱ្យបានមុនសប្តាហ៍ ទី ១ នៃខែ វិច្ឆិកា ឆ្នាំ ២០២២ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២២។

៣០-ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២៣ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបាន

សម្រាប់ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ ការចរចាថវិកាកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និងតាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) លើមូលដ្ឋាននៃគោលការណ៍ និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំថវិកា ក្នុងកម្រិតនៃពិតានកញ្ចប់ថវិកាឆ្នាំ ២០២៣ ដែលបានកំណត់ និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3.. ) ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៤- សេចក្តីសន្និដ្ឋាន

៣១-ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅជានាសម្រេចឱ្យបានជោគជ័យនូវគោលបំណងគោលនយោបាយ និងកម្មវិធីដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ក្នុងបរិការណ៍នៃការបន្សាំទៅនឹងផលវិបាកនៃជំងឺកូវីដ-១៩ និងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចដែលរងផលប៉ះពាល់ពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់ និងបន្ទាន់នានា ក្នុងគោលបំណងដើម្បីរក្សាលំនឹងសេដ្ឋកិច្ច តាមរយៈការបន្តដោះស្រាយបញ្ហាដែលនៅសេសសល់ពីវិបត្តិជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម, ការបន្តរក្សាលំនឹងជីវភាពប្រជាជន, ព្រមទាំងដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច តាមរយៈការបន្តបង្កើនភាពប្រកួតប្រជែង, ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ។

៣២-ទោះជាយ៉ាងណាក្តី ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈម្ចាស់ការ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ

ដើម្បីមិនត្រឹមតែអាចបង្កើនសក្ដានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដើម្បីបង្កើនភាពស័ក្ដិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣៣-ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០២២** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្ដើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា)។

ថ្ងៃ ព្រហ ៩ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០២២
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៤១១៣...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង របស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ចស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រកចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរងរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដូចមានសមាសភាពខាងក្រោម÷

១. លោកស្រី **ណោ ស៊ីថែន** ប្រធានការិយាល័យគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ជារជ្ជទេយ្យករចំណូល

២. លោកស្រី **ទ៊ែត រ៉ូហ្សេត** អនុប្រធានការិយាល័យគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ជារជ្ជទេយ្យករចំណូលរង។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខៈ....................................

ថ្ងៃ.................... ខែ.............. ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦...
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២០... ខែ...មេសា... ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៨៧១/១៨ ស.ត.ស.ព ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតសម្ភារៈវេចខ្ចប់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ណាតផាក (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១ៈ** អនុញ្ញាតឱ្យក្រុមហ៊ុន ណាតផាក (ខេមបូឌា) ឯ.ក (**NATPAK (CAMBODIA) CO., LTD.**) តំណាងដោយលោក **AU KA FAI KINSEN** សញ្ជាតិចិន(ហុងកុង) កាន់លិខិតឆ្លងដែនលេខ **HJ2146116** ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ បង្កើតរោងចក្រផលិតសម្ភារវេចខ្ចប់ ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្ភារវេចខ្ចប់ | ១៧០២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រផលិតសម្ភារវេចខ្ចប់ ណាតផាក (ខេមបូឌា) ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រ០៧៧ ឧស.កឱ.ប្រក.០២ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍
រដ្ឋលេខាធិការ

ហាន សុភា

__ចម្លងជូន៖__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តព្រះសីហនុ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
- អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
- រដ្ឋបាលស្រុកព្រៃនប់
- រដ្ឋបាលឃុំបិតត្រាំង និងឃុំរាម
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី